Ven. Members of the Sangha, Ven.  Theras
Valued Upasaka, valued Upasika

This is a Work Edition!
1.Edition 08.10.2021
Do not share it further except for editing and working purposes within the transcription project on sangham.net.
Only for personal use.

If you find any mistake or like to join the merits please feel invited to join here:
http://sangham.net/index.php/board,85.0.html

or Upasika Norum on sangham.net

Anumodana!

សូមថ្វាយបង្គំចំពោះព្រះសង្ឃ,
ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់

នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ!
1.Edition 08.10.2021
សូមកុំចែករំលែកបន្ថែមទៀត
ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net
និងកិច្ចការនេះ។
សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុស
លនេះ និងសូមប្រាប់ពួកយើងអំពីកំហុស
និងប្រើវេទិកានេះ:http://sangham.net/index.php/boar

d,85.0.html

ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net

សូមអនុមោទនា!

អភិធម្មបិដក

បដ្ឋាន អដ្ឋមភាគ

**ភាគទី១០១**

# អនុលោមទុកប្បដ្ឋាន

សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ។

## សញ្ញោជនទុកៈ

### បដិច្ចវារៈ

[១] សញ្ញោជនធម៌ (ធម៌ដែលចងសត្វទុកក្នុងវដ្តៈ) អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ មានសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យនូវកាមរាគសញ្ញោជនៈ ឥស្សាសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវបដិឃសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវបដិឃសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យនូវបដិឃសញ្ញោជនៈ ភវរាគសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវមានសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យភវរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យនូវវិចិកិច្ឆាសញ្ញោជនៈ។ នោសញ្ញោជនធម៌ (ធម៌មិនមែនជាសញ្ញោជនៈ) អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសញ្ញោជនៈ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ បណ្ឌិតគប្បីចងជាចក្កៈចុះ។ នោសញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១

ជានោសញ្ញោជនៈ នូវខន្ធ២... វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត១... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត។ សញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ អាស្រ័យនូវពួកនោសញ្ញោជនក្ខន្ធ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ពួកសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជានោសញ្ញោជនៈ នូវខន្ធ២...។ សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង បណ្ឌិតគប្បីចងជាចក្កៈចុះ។ នោសញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជានោសញ្ញោជនៈផង នូវពួកសញ្ញោជនៈផង នូវខន្ធ២...។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជានោសញ្ញោជនៈផង នូវកាមរាគសញ្ញោជនៈផង បណ្ឌិតគប្បីចងជាចក្កៈចុះ។

ក្នុងអារម្មណប្បច្ច័យ មិនមានរូបទេ។ ឯអធិបតិប្បច្ច័យ ដូចហេតុប្បច្ច័យដែរ មិនមានវិចិកិច្ឆាសញ្ញោជនៈទេ។ ព្រោះអនន្តរប្បច្ច័យ ព្រោះអវិគតប្បច្ច័យ។

[២] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩

ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៣] សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យវិចិកិច្ឆាសញ្ញោជនៈ។ នោសញ្ញោជនធម៌ អាស្រ័យនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ១ ជានោសញ្ញោជនៈ នូវខន្ធ២... រហូតដល់ពួកអសញ្ញសត្វ។ សញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវវិចិកិច្ឆាសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង។ សេចក្តីបំប្រួញ។ ដូចអាសវគោច្ឆកៈដែរ។ ឯនអារម្មណប្បច្ច័យទាំងអស់ បណ្ឌិតគប្បីរើឡើងផងចុះ

[៤] ក្នុងនហេតុប្បច្ច័យ មានវារៈ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បទទាំងអស់ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ។

[៦] ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះនហេតុប្បច្ច័យ... ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ៤។ កើតជាមួយនឹងសញ្ញោជនធម៌...។

**បច្ចយវារៈ**

[៧] សញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣ ដូចបដិច្ចវារៈដែរ។ នោសញ្ញោជនធម៌ ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ១ នឹងខន្ធ២... វត្ថុ ពឹងផ្អែកនឹងពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ នឹងមហាភូត១... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ពួកនោសញ្ញោជនក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ សញ្ញោជនធម៌ ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ ពឹងផ្អែកនឹងពួកនោសញ្ញោជនក្ខន្ធ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី សញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ១ នឹងខន្ធ២... ពួកសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ។ សញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងពួកសម្បយុត្តកក្ខន្ធផង

ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងវត្ថុផង បណ្ឌិតគប្បីចងជាចក្កៈចុះ។ នោសញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ១ផង នឹងពួកសញ្ញោជនៈផង នឹងខន្ធ២... (គប្បីចង) ជាចក្កៈចុះ ពួកនោសញ្ញោជនក្ខន្ធ ពឹងផ្អែកនឹងពួកសញ្ញោជនៈផង នឹងវត្ថុផង។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ១ផង នឹងកាមរាគសញ្ញោជនៈផង នឹងខន្ធ២... (គប្បីចង) ជាចក្កៈចុះ ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងវត្ថុផង (គប្បីចង) ជាចក្កៈចុះ។ សេចក្តីបំប្រួញ។

[៨] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៩] ក្នុងនហេតុប្បច្ច័យ មានវារៈ៤។ វត្ថុ ដែលបានត្រង់កន្លែងណាៗ បណ្ឌិតគប្បីធ្វើមិនឲ្យផ្សេងគ្នា ត្រង់កន្លែងនោះៗចុះ។ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

ការរាប់២យ៉ាងក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ។

**សំសដ្ឋវារៈ**

[១០] សញ្ញោជនធម៌ ច្រឡូកច្រឡំនឹងសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី

ច្រឡូកច្រឡំនឹងកាមរាគសញ្ញោជនៈ ឯពួកអរូប មានប្រស្នា៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះឯង។

**បញ្ហាវារៈ**

[១១] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ជាប្បច្ច័យនៃពួកសម្បយុត្តកសញ្ញោជនៈ ដោយហេតុប្បច្ច័យ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកសញ្ញោជនៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជានោសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ...។

[១២] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសញ្ញោជនៈកើតឡើង ព្រោះប្រារព្ធនូវពួកសញ្ញោជនៈ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកនោសញ្ញោជនក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវពួកសញ្ញោជនៈ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកសញ្ញោជនៈ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ នូវផល

ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ ផល និងការពិចារណា ពួកព្រះអរិយៈ (ពិចារណា) នូវពួកនោសញ្ញោជនកិលេស ដែលលះបង់ហើយ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ... ក្នុងកាលមុន... នូវចក្ខុ នូវវត្ថុ... នូវពួកនោសញ្ញោជនក្ខន្ធ ថាមិនទៀង... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនោសញ្ញោជនចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកនោសញ្ញោជនក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ នឹងពួកនោសញ្ញោជនក្ខន្ធ រាគៈ ប្រារព្ធនូវខន្ធនោះ... ទោមនស្សកើតឡើង។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ នឹងពួកនោសញ្ញោជនក្ខន្ធ ពួកសញ្ញោជនៈក្តី ពួកខន្ធប្រកបដោយសញ្ញោជនៈក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺបណ្ឌិតគប្បីប្រារព្ធធ្វើឲ្យមានវារៈ៣ ផងចុះ។

[១៣] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺបុគ្គលធ្វើនូវពួកសញ្ញោជនៈ ឲ្យជាទីគោរព ...មានវារៈ៣ មានការធ្វើឲ្យជាទីគោរពជាអារម្មណ៍។ នោសញ្ញោជនធម៌

ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល ...មានវារៈ៣។ អារម្មណាធិបតិ និងសហជាតាធិបតិ បណ្ឌិតគប្បីធ្វើ (ដោយអំណាច) នៃវារៈ៣ ទាំងគប្បីចែកជាវារៈ៣ចុះ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺបុគ្គលធ្វើនូវពួកសញ្ញោជនៈ និងពួកសម្បយុត្តកក្ខន្ធ ឲ្យជាទីគោរព ...មានវារៈ៣។

[១៤] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសញ្ញោជនៈមុនៗ ជាបច្ច័យនៃពួកសញ្ញោជនៈក្រោយៗ ដោយអនន្តរប្បច្ច័យ មានវារៈ៣។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោសញ្ញោជនក្ខន្ធមុនៗ ក្រោយ...។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោសញ្ញោជនក្ខន្ធមុនៗ នៃពួកសញ្ញោជនៈក្រោយៗ ...វារៈ២ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ៣។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយសមនន្តរប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៩។

[១៥] ...ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកសញ្ញោជនៈ ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ មានវារៈ៣យ៉ាងនេះ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិ

ឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ...។បេ។ នូវបញ្ញា នូវរាគៈ។បេ។ នូវសេចក្តីប្រាថ្នា ...អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ...។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយតំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ...។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ៣។

[១៦] នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺ(បុគ្គល) នូវចក្ខុ ...នូវវត្ថុ ថាមិនទៀង ...ទោមនស្សកើតឡើង បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកនោសញ្ញោជនក្ខន្ធ ដោយបុរេជាតប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយបុរេជាតប្បច្ច័យ

បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺ (បុគ្គល) នូវចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ រាគៈ ប្រារព្ធនូវវត្ថុនោះ ...ទោមនស្សកើតឡើង។ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសញ្ញោជនៈ ដោយបុរេជាតប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺ (បុគ្គល) នូវចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ។

[១៧] សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ១។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ។

[១៨] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ៩។

[១៩] នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយកម្មប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។ ជាបច្ច័យ ដោយអាហារប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ៩។

[២០] សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ បណ្ឌិតគប្បីចែកចុះ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ បណ្ឌិតគប្បីចែកចុះ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ

ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ បណ្ឌិតគប្បីចែកចុះ។

[២១] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ដូចគ្នានឹងបដិច្ចវារៈដែរ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺពួកនោសញ្ញោជនក្ខន្ធ ជាបច្ច័យនៃពួកសម្បយុត្តកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺ (បុគ្គល) នូវចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង វត្ថុជាបច្ច័យនៃពួកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺពួកនោសញ្ញោជនៈ ...សេចក្តីបំប្រួញ ដូចគ្នានឹងអាសវៈដែរ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ ដូចគ្នានឹងអាសវៈដែរ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ បណ្ឌិតគប្បីចែកចុះ ដូចគ្នានឹងអាសវៈដែរ។

សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ បណ្ឌិតគប្បីចែកចុះ ដូចគ្នានឹងអាសវៈដែរ។

[២២] ក្នុងហេតុប្បច្ច័យ មានវារៈ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនិត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[២៣] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ

ដោយឥន្ទ្រិយប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[២៤] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[២៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៤។ សេចក្តីបំប្រួញ។ ...ក្នុងនមគ្គប្បច្ច័យ មានវារៈ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ៤។

[២៦] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ អនុលោមមាតិកា ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ សញ្ញោជនទុកៈ។

## សញ្ញោជនិយទុកៈ

## បដិច្ចវារៈ

[២៧] សញ្ញោជនិយធម៌ (ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ) អាស្រ័យនូវសញ្ញោជនិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជាសញ្ញោជនិយៈ នូវខន្ធ២ ...វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត១...។ ដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ។

ចប់ សញ្ញោជនិយទុកៈ។

## សញ្ញោជនសម្បយុត្តទុកៈ

## បដិច្ចវារៈ

[២៨] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ នូវខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ នូវខន្ធ២ ...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ នូវខន្ធ២ ...ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ មានបដិសន្ធិ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី

ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ២ ...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ២...។

[២៩] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺនូវខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ ...នូវខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ក្តី មោហៈក្តី អាស្រ័យនូវខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈ នូវខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ

អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ នូវខន្ធ២ ...ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ២...។

[៣០] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមានវារៈ៣។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមានវារៈ១។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈផង នូវពួកមហាភូតផង។ សេចក្តីបំប្រួញ។

[៣១] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ៦ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៩ ក្នុងឈានប្បច្ច័យ មានវារៈ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ

មានវារៈ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៦ ក្នុងវិគតប្បច្ច័យ មានវារៈ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៣២] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺនូវអហេតុកក្ខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ ... ដរាបដល់ពួកអសញ្ញសត្វ។

[៣៣] ក្នុងនហេតុប្បច្ច័យ មានវារៈ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៣៤] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤

ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៣៥] ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ ...ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ២ ក្នុងអវិគតប្បច្ច័យ មានវារៈ៣។ ឯសហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ។

**បច្ចយវារៈ**

[៣៦] ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនូវធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣ ដូចគ្នានឹងបដិច្ចវារៈដែរ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺដរាបដល់បដិសន្ធិ នូវមហាភូត១ ...ពួកខន្ធដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ មោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយសញ្ញោជនៈផង នឹងវត្ថុផង នឹងខន្ធ២ ...ខន្ធ៣

ពឹងផ្អែកនឹងខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយសញ្ញោជនៈផង នឹងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយសញ្ញោជនៈផង នឹងវត្ថុផង នឹងខន្ធ២ ...ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយសញ្ញោជនៈផង នឹងពួកមហាភូតផង ខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ២...។

[៣៧] ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ៣ ដូចគ្នានឹងបដិច្ចវារៈដែរ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺដរាបដល់បដិសន្ធិ ពួកខន្ធដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកខន្ធដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។

ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ពឹងផ្អែកនឹងវត្ថុ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយសញ្ញោជនៈផង នឹងវត្ថុផង នឹងខន្ធ២ ...ខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងវត្ថុផង។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងវត្ថុផង នឹងខន្ធ២...។

[៣៨] ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ។ ព្រោះអវិគតប្បច្ច័យ។

[៣៩] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៤០] ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលច្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺនឹងអហេតុកក្ខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ ...ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ ដែលប្រាសចាកសញ្ញោជនៈក្តី មោហៈ ដែលច្រឡំដោយឧទ្ធច្ចៈក្តី ពឹងផ្អែកនឹងវត្ថុ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងវត្ថុ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆាផង នឹងវត្ថុផង។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងវត្ថុផង។ សេចក្តីបំប្រួញ។

[៤១] ក្នុងនហេតុប្បច្ច័យ មានវារៈ៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៧

ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៤២] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ។

[៤៣] ក្នុងអារម្មណប្បច្ច័យ មានវារៈ៦ ព្រោះនហេតុប្បច្ច័យ ...ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៦ ក្នុងមគ្គប្បច្ច័យ មានវារៈ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ៦។

ឯនិស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ។

**សំសដ្ឋវារៈ**

[៤៤] ធម៌ដែលប្រកបដោយសញ្ញោជនៈ ច្រឡូកច្រឡំនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡូកច្រឡំនឹងខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ នឹងខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ច្រឡូកច្រឡំនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡូកច្រឡំនឹងខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ នឹងខន្ធ២ ...ក្នុងខណៈនៃបដិសន្ធិ...។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ច្រឡូកច្រឡំនឹងធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ច្រឡូកច្រឡំនឹងមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ច្រឡូកច្រឡំនឹងធម៌ ដែលប្រកបដោយសញ្ញោជនៈផង នឹងធម៌ដែលប្រាសចាកសញ្ញោជនៈផង

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡូកច្រឡំនឹងខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ២...។ សេចក្តីបំប្រួញ។

[៤៥] ក្នុងហេតុប្បច្ច័យ មានវារៈ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ៦។

[៤៦] ក្នុងនហេតុប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៦ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦។ ការរាប់ទាំងពីរយ៉ាងក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើផងចុះ។

**បញ្ហាវារៈ**

[៤៧] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង

នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ មានបដិសន្ធិដែរ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ ដែលប្រាសចាកសញ្ញោជនៈផង ដោយហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[៤៨] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រាសចាកសញ្ញោជនៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល ...នូវឧបោសថកម្ម ...ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងការពិចារណា ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ដែលលះបង់ហើយ ជាកិលេសដែលប្រាសចាកសញ្ញោជនៈ

ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន នូវចក្ខុ ...នូវវត្ថុ ...ឃើញច្បាស់នូវពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈផង នូវមោហៈផង ថាមិនទៀង ...ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយចិត្ត ដែលប្រាសចាកសញ្ញោជនៈ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ រូបាយតនៈ ...ផោដ្ឋព្វាយតនៈ ...ពួកខន្ធដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...នូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ នឹងពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈផង នឹងមោហៈផង រាគៈ ប្រារព្ធនូវខន្ធនោះ ...ទោមនស្សកើតឡើង។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ ...នូវវត្ថុ ...ពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈផង នូវមោហៈផង។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រាសចាកសញ្ញោជនៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង។ មូល

បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង។

[៤៩] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវរាគៈ ...នូវទិដ្ឋិ ...បុគ្គលធ្វើឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវធម៌នោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល ...នូវឧបោសថកម្ម ...ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា នូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន ...ពួកព្រះអរិយៈ (ចេញ) អំពីមគ្គ ...នូវផល ...នូវព្រះនិព្វាន ...ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។

ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង នូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលធ្វើនូវពួកក្ខន្ធ ដែលប្រាសចាកសញ្ញោជនៈ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង។

[៥០] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ប្រាសចាកសញ្ញោជនៈផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធមុនៗ ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យក្រោយ...។បេ។ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ

ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃមោហៈក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ

ដោយសហជាតប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ៦។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៩។

[៥១] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន។បេ។ ញ៉ាំងសមាបត្តិឲ្យកើតឡើង នូវសីល...។បេ។ នូវបញ្ញា កាយិកសុខ កាយិកទុក្ខ និងសេនាសនៈ ...បុគ្គលអាស្រ័យនូវមោហៈ ហើយឲ្យនូវទាន។បេ។ ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា។បេ។ សេនាសនៈ និងមោហៈ ជាបច្ច័យនៃសទ្ធា។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ

និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ នូវបញ្ញា នូវកាយិកសុខ។បេ។ នូវសេនាសនះ ...អាស្រ័យនូវមោហៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនះ និងមោហៈ ជាបច្ច័យនៃរាគៈ។បេ។ នៃសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ ដែលប្រាសចាកសញ្ញោជនៈផង ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺសទ្ធា។បេ។ បញ្ញា កាយិកសុខ។បេ។ សេនាសនះ និងមោហៈ ជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ និងធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ

ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ។

[៥២] ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ...បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកខន្ធដែលប្រាសចាកសញ្ញោជនៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...បុគ្គលត្រេកអរ រីករាយ នឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ...ទោមនស្ស កើតឡើង។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយបុរេជាតប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុ វត្ថុ ជាបច្ច័យនៃពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ។

[៥៣] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌

ដែលប្រាសចាកសញ្ញោជនៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺពួកខន្ធ ដែលប្រាសចាកសញ្ញោជនៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ។

[៥៤] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអាសេវនប្បច្ច័យ គឺមានវារៈ៩ ការពិចារណាក្តី ការចេញក្តី មិនមានទេ។

[៥៥] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយកម្មប្បច្ច័យ គឺចេតនា ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយកម្មប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺចេតនា ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ចេតនា ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយកម្មប្បច្ច័យ គឺចេតនា ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនា ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង

ដោយកម្មប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត ចេតនា ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ...។ ឯនានាខណិកៈ គឺចេតនាដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។

[៥៦] ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។

[៥៧] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈ ដោយអាហារប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ៦។

[៥៨] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលប្រកបដោយសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធ

ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយវិប្បយុត្តប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។

[៥៩] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ដូចគ្នានឹងបដិច្ចវារៈដែរ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ ឯសហជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអត្ថិប្បច្ច័យ គឺខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...ខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃខន្ធ៣ផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២...។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ បណ្ឌិតគប្បីឲ្យពិស្តារចុះ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ។ បុរេជាត គឺនូវចក្ខុ ...នូវវត្ថុ

បុគ្គលត្រេកអរ រីករាយ រាគៈ ...ប្រារព្ធនូវវត្ថុនោះ ទោមនស្សកើតឡើង វត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ បុរេជាត គឺនូវចក្ខុ ...ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ ដែលប្រកបដោយសញ្ញោជនៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២ ...ខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២...។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈក្តី មោហៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលច្រឡំដោយឧទ្ធច្ចៈក្តី វត្ថុក្តី ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈក្តី

រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...សហជាត គឺខន្ធ១ ដែលច្រឡំដោយឧទ្ធច្ចៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ៣ផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ខន្ធ២...។ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយវិគតប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ។

[៦០] ក្នុងហេតុប្បច្ច័យ មានវារៈ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៤ ក្នុងឈានប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៦១] ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ

ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រាសចាកសញ្ញោជនៈផង

ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[៦២] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[៦៣] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៦ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៦។ សេចក្តីបំប្រួញ។ ...ក្នុងនមគ្គប្បច្ច័យ មានវារៈ៦ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៦ ក្នុងនោវិគតប្បច្ច័យ មានវារៈ៦។

[៦៤] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ...ព្រោះនហេតុប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ...អនុលោមបទ បណ្ឌិតគប្បីរាប់ចុះ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ សញ្ញោជនសម្បយុត្តទុកៈ។

## សញ្ញោជនសញ្ញោជនិយទុកៈ

### បដិច្ចវារៈ

[៦៥] ធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវកាមរាគសញ្ញោជនៈ បណ្ឌិតគប្បីចងជាចក្កៈចុះ។ ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសញ្ញោជនៈ។ ធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក្តី ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ជាសញ្ញោជនៈ

ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ ចក្កៈ។ ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ នូវខន្ធ២ ...មានបដិសន្ធិ ដរាបដល់ពួកមហាភូត។ ធម៌ជាសញ្ញោជនៈទាំងជាប្រយោជន៍ដល់សញ្ញោជនៈ អាស្រ័យនូវធម៌ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ អាស្រ័យនូវពួកខន្ធជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ។ ធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក្តី ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ពួកសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ នូវខន្ធ២...។ ធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង នូវធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង ចក្កៈ។ ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង នូវធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី

ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ដែលជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង នូវពួកសញ្ញោជនៈផង នូវខន្ធ២...។ ធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក្តី ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង នូវធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ ដែលជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង នូវកាមរាគសញ្ញោជនៈផង នូវខន្ធ២ ...បណ្ឌិតគប្បីចងជាចក្កៈចុះ។ ទុកៈនេះឯង វៀរលែងតែលោកុត្តរទុកៈចេញ បណ្ឌិតគប្បីឲ្យពិស្តារដូចបឋមទុកៈ ក្នុងសញ្ញោជនគោច្ឆកៈចុះ មិនមានការធ្វើឲ្យផ្សេងគ្នាទេ។

ចប់ សញ្ញោជនសញ្ញោជនិយទុកៈ។

## សញ្ញោជនសញ្ញោជនសម្បយុត្តទុកៈ

### បដិច្ចវារៈ

[៦៦] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកសញ្ញោជនៈ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក្តី ធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី

អាស្រ័យនូវកាមរាគសញ្ញោជនៈ។ ធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ នូវខន្ធ២...។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក្តី ធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ពួកសញ្ញោជនៈក្តី អាស្រ័យនូវខន្ធ១ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ នូវខន្ធ២...។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង នូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង ចក្កៈ។ ធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង នូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង នូវពួកសញ្ញោជនៈផង នូវខន្ធ២...។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក្តី ធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី អាស្រ័យនូវធម៌ជាសញ្ញោជនៈ

ទាំងប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវខន្ធ១ ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង នូវកាមរាគសញ្ញោជនៈផង នូវខន្ធ២ ...ចក្កៈ។

[៦៧] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៦៨] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវវិចិកិច្ឆាសញ្ញោជនៈ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង នូវធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវវិចិកិច្ឆាសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង។

[៦៩] ក្នុងនហេតុប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩។

ការរាប់២យ៉ាងក្រៅនេះក្តី សហជាតវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ។

**បញ្ហាវារៈ**

[៧០] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺកាមរាគសញ្ញោជនៈ ជាបច្ច័យនៃទិដ្ឋិសញ្ញោជនៈផង នៃអវិជ្ជាសញ្ញោជនៈផង ដោយហេតុប្បច្ច័យ ចក្កៈ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង នៃធម៌ប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ដោយហេតុប្បច្ច័យ គឺកាមរាគសញ្ញោជនៈ ជាបច្ច័យនៃទិដ្ឋិសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយហេតុប្បច្ច័យ។

[៧១] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺពួកសញ្ញោជនៈ ប្រារព្ធនូវពួកសញ្ញោជនៈ ទើបកើតឡើង។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ប្រារព្ធនូវពួកសញ្ញោជនៈ ទើបកើតឡើង។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកសញ្ញោជនៈក្តី ពួកខន្ធដែលប្រកបដោយសញ្ញោជនៈក្តី ប្រារព្ធនូវពួកសញ្ញោជនៈ ទើបកើតឡើង។ ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ប្រារព្ធនូវពួកខន្ធ

ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង។ ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺពួកសញ្ញោជនៈ ប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង។ ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង នៃធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផង ដោយអារម្មណប្បច្ច័យ គឺពួកសញ្ញោជនៈក្តី ពួកខន្ធដែលប្រកបដោយសញ្ញោជនៈក្តី ប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ទើបកើតឡើង។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ គឺមានវារៈ៣។

[៧២] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺមានវារៈ៣។ ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ គឺមានវារៈ៣។ អារម្មណាធិបតិក្តី សហជាតាធិបតិក្តី បណ្ឌិតគប្បីធ្វើក្នុងបញ្ហាទាំង៣នេះផងចុះ។ ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈក្តី

ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺមានវារៈ៣។

[៧៣] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអនន្តរប្បច្ច័យ គឺមានវារៈ៩ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ទាំងការចែកក៏មិនមាន ដូចគ្នានឹងអារម្មណប្បច្ច័យដែរ។ ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ៩ (បច្ច័យទាំងឡាយ) បណ្ឌិតគប្បីធ្វើដោយអារម្មណន័យចុះ។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ គឺមានវារៈ៩។

[៧៤] ធម៌ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ដោយកម្មប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយអាហារប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយវិគតប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអវិគតប្បច្ច័យ គឺមានវារៈ៩។

[៧៥] ក្នុងហេតុប្បច្ច័យ មានវារៈ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩

ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៧៦] ធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ជាបច្ច័យនៃធម៌ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ។ សេចក្តីបំប្រួញ។ បញ្ហាទាំង៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ (បច្ច័យទាំងឡាយ) បណ្ឌិតគប្បីឲ្យប្រែប្រួល ក្នុងបទទាំង៣ ឯនានាខណិកៈ មិនមានឡើយ។

[៧៧] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[៧៨] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៣។ សេចក្តីបំប្រួញ។ ...ក្នុងនមគ្គប្បច្ច័យ មានវារៈ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៧៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ពួកអនុលោមបទ បណ្ឌិតគប្បីធ្វើចុះ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ សញ្ញោជនសញ្ញោជនសម្បយុត្តទុកៈ។

## សញ្ញោជនវិប្បយុត្តសញ្ញោជនិយទុកៈ

## បដិច្ចវារៈ

[៨០] ធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី

អាស្រ័យនូវខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ នូវខន្ធ២ ...មានបដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ និងពួកមហាភូត។ ធម៌ដែលប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ នូវខន្ធ២...។ នូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ...។ បញ្ហាទាំង២ បណ្ឌិតគប្បីធ្វើផងចុះ។ ទុកៈនេះ ដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ។

ចប់ សញ្ញោជនវិប្បយុត្តសញ្ញោជនិយទុកៈ។

**គន្ថទុកៈ**

**បដិច្ចវារៈ**

[៨១] គន្ថធម៌ (ធម៌ជាគ្រឿងដោតក្រង) អាស្រ័យនូវគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិវេសកាយគន្ថៈ (កាយគន្ថៈ គឺសេចក្តីប្រកាន់មាំថានេះជារបស់ពិត) ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ (ទើបកើតឡើង)។ នោគន្ថធម៌ (ធម៌មិនមែនជាគ្រឿងដោតក្រង) អាស្រ័យនូវគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវគន្ថធម៌ (ទើបកើតឡើង)។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី អាស្រ័យនូវគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ (ទើបកើតឡើង) (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ នោគន្ថធម៌ អាស្រ័យនូវនោគន្ថធម៌ ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាគន្ថៈ នូវខន្ធ២ ...ក្នុងខណៈនៃបដិសន្ធិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត១ ...(ទើបកើតឡើង)។ គន្ថធម៌ អាស្រ័យនូវនោគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺគន្ថៈ អាស្រ័យនូវពួកខន្ធមិនមែនជាគន្ថៈ (ទើបកើតឡើង)។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី អាស្រ័យនូវនោគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកគន្ថៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាគន្ថៈ នូវខន្ធ២ ...(ទើបកើតឡើង)។ គន្ថធម៌ អាស្រ័យនូវគន្ថធម៌ផង នូវនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈផង នូវពួកសម្បយុត្តកក្ខន្ធផង (ទើបកើតឡើង) (បណ្ឌិតគប្បីធ្វើ) ជាចក្កៈ។ នោគន្ថធម៌ អាស្រ័យនូវគន្ថធម៌ផង នូវនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាគន្ថៈផង នូវពួកគន្ថៈផង នូវខន្ធ២ ... (ទើបកើតឡើង)។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី អាស្រ័យនូវគន្ថធម៌ផង នូវនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង អភិជ្ឈាកាយគន្ថៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាគន្ថៈផង នូវសីលព្វតបរាមាសកាយគន្ថៈផង នូវខន្ធ២ ... (ទើបកើតឡើង បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។ ព្រោះអារម្មណប្បច្ច័យ ព្រោះអវិគតប្បច្ច័យ។

[៨២] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៨៣] នោគន្ថធម៌ អាស្រ័យនូវនោគន្ថធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាគន្ថៈ

ជាអហេតុកៈ នូវខន្ធ២ ...អហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ (ទើបកើតឡើង)។

[៨៤] នោគន្ថធម៌ អាស្រ័យនូវគន្ថធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកគន្ថៈ (ទើបកើតឡើង)។ នោគន្ថធម៌ អាស្រ័យនូវនោគន្ថធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ អាស្រ័យនូវពួកខន្ធមិនមែនជាគន្ថៈ (ទើបកើតឡើង)។ នោគន្ថធម៌ អាស្រ័យនូវគន្ថធម៌ផង នូវនោគន្ថធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកគន្ថៈផង នូវពួកសម្បយុត្តកក្ខន្ធផង (ទើបកើតឡើង)។ សេចក្តីបំប្រួញ។ ព្រោះនអធិបតិប្បច្ច័យ មានវារៈ៩។ ព្រោះនអនន្តរប្បច្ច័យ មានវារៈ៣។ ព្រោះនសមនន្តរប្បច្ច័យ មានវារៈ៣។ ព្រោះនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣។ ព្រោះនឧបនិស្សយប្បច្ច័យ មានវារៈ៣។

[៨៥] គន្ថធម៌ អាស្រ័យនូវគន្ថធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិវេសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ ក្នុងអរូប (ទើបកើតឡើង)។ ក្នុងអរូប មិនមានសីលព្វតបរាមាសៈទេ ប្រស្នាទាំង៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ។ ព្រោះនបច្ឆាជាតប្បច្ច័យ មានវារៈ៩។ ព្រោះនអាសេវនប្បច្ច័យ មានវារៈ៩។ ព្រោះនកម្មប្បច្ច័យ មានវារៈ៣។ ព្រោះនវិបាកប្បច្ច័យ មានវារៈ៩។ ព្រោះនអាហារប្បច្ច័យ មានវារៈ១។ ព្រោះនឥន្ទ្រិយប្បច្ច័យ មានវារៈ១។ ព្រោះនឈានប្បច្ច័យ មានវារៈ១។ ព្រោះនមគ្គប្បច្ច័យ មានវារៈ១។ ព្រោះនសម្បយុត្តប្បច្ច័យ មានវារៈ៣។ ព្រោះនវិប្បយុត្តប្បច្ច័យ មានវារៈ៩។ ព្រោះនោនត្ថិប្បច្ច័យ មានវារៈ៣។ ព្រោះនោវិគតប្បច្ច័យ មានវារៈ៣។

[៨៦] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៨៧] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ។

[៨៨] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអនន្តរប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១។

សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។

**បច្ចយវារៈ**

[៨៩] គន្ថធម៌ ពឹងផ្អែកនឹងគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ នោគន្ថធម៌ ពឹងផ្អែកនឹងនោគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាគន្ថៈ នឹងខន្ធ២ ...ក្នុងខណៈនៃបដិសន្ធិ វត្ថុពឹងផ្អែកនឹងពួកខន្ធ ពួកខន្ធពឹងផ្អែកនឹងវត្ថុ នឹងមហាភូត១ ...ពួកខន្ធមិនមែនជាគន្ថៈ ពឹងផ្អែកនឹងវត្ថុ (ទើបកើតឡើង)។ គន្ថធម៌ ពឹងផ្អែកនឹងនោគន្ថធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថៈ ពឹងផ្អែកនឹងពួកខន្ធមិនមែនជាគន្ថៈ ពួកគន្ថៈ ពឹងផ្អែកនឹងវត្ថុ (ទើបកើតឡើង)។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ពឹងផ្អែកនឹងនោគន្ថធម៌

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកគន្ថៈផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាគន្ថៈ នឹងខន្ធ២ ...ពួកគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង ពឹងផ្អែកនឹងវត្ថុ (ទើបកើតឡើង)។ គន្ថធម៌ ពឹងផ្អែកនឹងគន្ថធម៌ផង នឹងនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ ពឹងផ្អែកនឹងសីលព្វតបរាមាសកាយគន្ថៈផង នឹងពួកសម្បយុត្តកក្ខន្ធផង (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ អភិជ្ឈាកាយគន្ថៈ ពឹងផ្អែកនឹងសីលព្វតបរាមាសកាយគន្ថៈផង នឹងវត្ថុផង (ទើបកើតឡើង) (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ នោគន្ថធម៌ ពឹងផ្អែកនឹងគន្ថធម៌ផង នឹងនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាគន្ថៈផង នឹងពួកគន្ថៈផង នឹងខន្ធ២ ...ពួកខន្ធមិនមែនជាគន្ថៈ ពឹងផ្អែកនឹងពួកគន្ថៈផង នឹងវត្ថុផង (ទើបកើតឡើង)។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ពឹងផ្អែកនឹងគន្ថធម៌ផង នឹងនោគន្ថធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង អភិជ្ឈាកាយគន្ថៈផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាគន្ថៈផង នឹងសីលព្វតបរាមាសកាយគន្ថៈផង នឹងខន្ធ២ ... (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ អភិជ្ឈាកាយគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងសីលព្វតបរាមាសកាយគន្ថៈផង នឹងវត្ថុផង ទើបកើតឡើង (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។

[៩០] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[៩១] នោគន្ថធម៌ ពឹងផ្អែកនឹងនោគន្ថធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាគន្ថៈ ជាអហេតុកៈ នឹងខន្ធ២ ...បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ

ពួកខន្ធមិនមែនជាគន្ថៈ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង (ទើបកើតឡើង)។ សេចក្ដីបំប្រួញ។

[៩២] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ។

[៩៣] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[៩៤] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអវិគតប្បច្ច័យ មានវារៈ១។ សូម្បីនិស្សយវារៈ ក៏ប្រហែលគ្នានឹងបច្ច័យវារៈដែរ។ សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើឲ្យជាប្រស្នា៩ ឯរូបមិនមានទេ។

**បញ្ហាវារៈ**

[៩៥] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ជាបច្ច័យនៃសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ បដិសន្ធិ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយហេតុប្បច្ច័យ

គឺពួកហេតុមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈផង ជានោគន្ថៈផង ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃនោគន្ថធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈផង ជានោគន្ថធម៌ផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈក្តី ជានោគន្ថៈក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[៩៦] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ គឺពួកគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិត គប្បីធ្វើផងចុះ ពួកខន្ធមិនមែនជាគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិតគប្បីធ្វើផងចុះ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...បុគ្គលពិចារណានូវកុសលកម្មនោះ ពិចារណានូវពួកកុសលកម្ម ដែលបានសន្សំទុកល្អហើយ ក្នុងកាលមុខ ចេញអំពីឈាន ហើយពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងការពិចារណា ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ (ពិចារណា) នូវពួកកិលេសមិនមែនជាគន្ថៈ ដែលលះបង់ហើយ ...ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ នូវពួកខន្ធមិនមែនជាគន្ថៈ ថាមិនទៀង ...ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ

ដឹងនូវចិត្តរបស់បុគ្គល អ្នកព្រមព្រៀងដោយចិត្ត មិនមែនជាគន្ថៈដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកខន្ធមិនមែនជាគន្ថៈ ជាបច្ច័យនៃកិរិយាពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយត្រេកអរ រីករាយ ចំពោះកុសលកម្មនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ។បេ។ ទោមនស្សកើតឡើង ដែលសន្សំទុកល្អហើយ ក្នុងកាលមុន ...ចេញអំពីឈាន (ហើយពិចារណា) នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ចំពោះពួកខន្ធមិនមែនជាគន្ថៈ រាគៈ កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។បេ។ ទោមនស្សកើតឡើង។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយត្រេកអរ រីករាយចំពោះកុសលកម្មនោះ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ ដែលខ្លួនសន្សំទុកល្អហើយ ក្នុងកាលមុន ...ចេញអំពីឈាន (ហើយពិចារណា) នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ចំពោះពួកខន្ធមិនមែនជាគន្ថៈ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ គឺមានវារៈ៣ ដែលបណ្ឌិតត្រូវប្រារព្ធធ្វើ។

[៩៧] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអធិបតិប្បច្ច័យ គឺមានវារៈ៣ ប្រហែលគ្នានឹងអារម្មណប្បច្ច័យ មានអារម្មណ៍ជាទីគោរព ដែលបណ្ឌិតគប្បីធ្វើ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអធិបតិប្បច្ច័យ

បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...ពួកព្រះអរិយៈ អំពីមគ្គ ...នូវផល ...នូវព្រះនិព្វាន ...ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ...នូវវត្ថុ ...ធ្វើនូវពួកខន្ធមិនមែនជាគន្ថៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ដែលសន្សំល្អហើយ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ធ្វើនូវពួកខន្ធមិនមែនជាគន្ថៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ចំពោះខន្ធនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាគន្ថៈ ជាបច្ច័យនៃពួកគន្ថៈ ដោយអធិបតិប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...ធ្វើនូវពួកខន្ធមិនមែនជាគន្ថៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺមានវារៈ៣។

[៩៨] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអនន្តរប្បច្ច័យ គឺពួកគន្ថៈមុនៗ ជាបច្ច័យនៃពួកគន្ថៈក្រោយៗ ដោយអនន្តរប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអនន្តរប្បច្ច័យ គឺពួកគន្ថៈមុនៗ ជាបច្ច័យនៃពួកខន្ធមិនមែនជាគន្ថៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកគន្ថៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកគន្ថៈមុនៗ ជាបច្ច័យនៃពួកគន្ថៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ៣ ការរំពឹងពីរយ៉ាង បណ្ឌិតគប្បីធ្វើចុះ វារៈជាបឋម មិនមានទេ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ៣ វុដ្ឋានៈ១ បណ្ឌិតគប្បីធ្វើ ក្នុងវារៈជាកណ្តាល។ គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយសមនន្តរប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ៩។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៩។

[៩៩] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកគន្ថៈ (ជាបច្ច័យ) នៃពួកគន្ថៈ ...មានវារៈ៣។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន។បេ។ ដំឡើងនូវមានៈ ប្រកាន់នូវទិដ្ឋិ នូវសីល ...។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ (ជាបច្ច័យ) នៃសទ្ធា។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ

គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃពួកគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ។ គន្ថធម៌ក្តី នៃនោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ បានដល់វារៈទាំង៣ ដែលបណ្ឌិតគប្បីធ្វើ ដោយន័យដូចជាអារម្មណប្បច្ច័យដែរ។

[១០០] នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...នូវវត្ថុ ថាមិនទៀង ...ទោមនស្សកើតឡើង (បុគ្គល) ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធមិនមែនជាគន្ថៈ ដោយបុរេជាតប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គល នូវចក្ខុ ...ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ។បេ។ ទោមនស្សកើតឡើង។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកគន្ថៈ ដោយបុរេជាតប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង

នៃនោគន្ថធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គល នូវចក្ខុ ...ត្រេកអរ រីករាយចំពោះវត្ថុ ប្រារព្ធនូវវត្ថុនោះ រាគៈកើតឡើង ទិដ្ឋិ...។បេ។ ទោមនស្សកើតឡើង ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកគន្ថៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ។ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ គឺមានវារៈ៩។

[១០១] នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺចេតនា មិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺចេតនា មិនមែនជាគន្ថៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយកម្មប្បច្ច័យ គឺចេតនាមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយកម្មប្បច្ច័យ គឺចេតនាមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។ ជាបច្ច័យ ដោយអាហារប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយឈានប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ មានវារៈ៩។

[១០២] គន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌

ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកគន្ថៈ ដោយវិប្បយុត្តប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុជាបច្ច័យនៃពួកគន្ថៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃនោគន្ថធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។

[១០៣] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ គន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សហជាត គឺពួកគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺពួកគន្ថៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺពួកខន្ធមិនមែនជាគន្ថៈ ជាបច្ច័យនៃពួកគន្ថៈ ដោយអត្ថិប្បច្ច័យ។ បុរេជាត គឺនូវចក្ខុ ...ត្រេកអរ រីករាយចំពោះវត្ថុ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ។បេ។ វត្ថុ ជាបច្ច័យនៃពួកគន្ថៈ ដោយអត្ថិប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ មិនមែនជាគន្ថៈ ជាបច្ច័យនៃខន្ធ៣ផង នៃពួកគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺនូវចក្ខុ ...ត្រេកអរ រីករាយចំពោះវត្ថុ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ វត្ថុ ជាបច្ច័យនៃពួកគន្ថៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ។

គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺសីលព្វតបរាមាសកាយគន្ថៈផង សម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃអភិជ្ឈាកាយគន្ថៈ ដោយអត្ថិប្បច្ច័យ (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ សហជាត គឺសីលព្វតបរាមាសកាយគន្ថៈផង វត្ថុផង ជាបច្ច័យនៃអភិជ្ឈាកាយគន្ថៈ ដោយអត្ថិប្បច្ច័យ (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃនោគន្ថធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺខន្ធ១ មិនមែនជាគន្ថៈក្តី ពួកគន្ថៈក្តី ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...សហជាត គឺពួកគន្ថៈផង វត្ថុផង ជាបច្ច័យនៃពួកខន្ធមិនមែនជាគន្ថៈ ដោយអត្ថិប្បច្ច័យ សហជាត គឺពួកគន្ថៈផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺពួកគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃបុរេជាត កាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ថៈផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ថៈផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ មិនមែនជាគន្ថៈផង សីលព្វតបរាមាសកាយគន្ថៈផង ជាបច្ច័យនៃខន្ធ៣ផង នៃអភិជ្ឈាកាយគន្ថៈផង នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ សហជាត គឺសីលព្វតបរាមាសកាយគន្ថៈផង វត្ថុផង ជាបច្ច័យនៃអភិជ្ឈាកាយគន្ថៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។

[១០៤] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងប្បច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣

ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១០៥] គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ គន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃនោគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នោគន្ថធម៌ ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃនោគន្ថធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ

ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ គន្ថធម៌ក្តី នោគន្ថធម៌ក្តី ជាបច្ច័យនៃគន្ថធម៌ផង នៃនោគន្ថធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[១០៦] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[១០៧] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ មូល៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ៩។

[១០៨] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ អនុលោមបទទាំងឡាយ បណ្ឌិតគប្បីធ្វើឲ្យបរិបូណ៌ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ គន្ថទុកៈ។

## គន្ថនិយទុកៈ

## បដិច្ចវារៈ

[១០៩] គន្ថនិយធម៌ (ធម៌ដែលគួរដល់គន្ថៈ) អាស្រ័យនូវគន្ថនិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ១ ជាគន្ថនិយៈ...។ សេចក្តីបំប្រួញ។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈ យ៉ាងណា បណ្ឌិតគប្បីចែករំលែកយ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ។

ចប់ គន្ថនិយទុកៈ។

## គន្ថសម្បយុត្តទុកៈ

## បដិច្ចវារៈ

[១១០] គន្ថសម្បយុត្តធម៌ (ធម៌ដែលប្រកបដោយគន្ថៈ) អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជាគន្ថសម្បយុត្ត នូវខន្ធ២...។ គន្ថវិប្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកគន្ថសម្បយុត្តក្ខន្ធ លោភៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ បដិឃៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយទោមនស្ស។ ពួកគន្ថសម្បយុត្តធម៌ក្តី ពួកគន្ថវិប្បយុត្តធម៌ក្តី អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រកបដោយគន្ថៈ នូវខន្ធ២ ...ខន្ធ៣ផង លោភៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ នូវខន្ធ២ ...ខន្ធ៣ផង បដិឃៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រកបដោយទោមនស្ស នូវខន្ធ២...។ គន្ថវិប្បយុត្តធម៌ អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែប្រាសចាកគន្ថៈ នូវខន្ធ២ ...ចិត្តសមុដ្ឋានរូប អាស្រ័យនូវលោភៈ ដែលប្រាសចាកទិដ្ឋិ ចិត្តសមុដ្ឋានរូប អាស្រ័យនូវបដិឃៈ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ...។ សេចក្តីបំប្រួញ។ គន្ថសម្បយុត្តធម៌ អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវលោភៈ ដែប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវបដិឃៈ។ ពួកគន្ថសម្បយុត្តធម៌ក្តី ពួកគន្ថវិប្បយុត្តធម៌ក្តី អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបដិឃៈ។ គន្ថសម្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ផង នូវគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈផង នូវលោភៈផង នូវខន្ធ២ ...ខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង នូវខន្ធ២...។ គន្ថវិប្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ផង នូវគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយគន្ថៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈផង នូវលោភៈផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង។ ពួកគន្ថសម្បយុត្តធម៌ក្តី ពួកគន្ថវិប្បយុត្តធម៌ក្តី អាស្រ័យនូវគន្ថសម្បយុត្តធម៌ផង នូវគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈផង នូវលោភៈផង នូវខន្ធ២ ...ខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង នូវខន្ធ២...។

[១១១] គន្ថសម្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រកបដោយគន្ថៈ នូវខន្ធ២...។ គន្ថវិប្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺលោភៈ អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ បដិឃៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយទោមនស្ស។ ពួកគន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី អាស្រ័យនូវគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ផង លោភៈផង អាស្រ័យនូវខន្ធ១ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ នូវខន្ធ២ ...ខន្ធ៣ផង បដិឃៈផង អាស្រ័យនូវខន្ធ១ ដែលប្រកបដោយទោមនស្ស នូវខន្ធ២...។ គន្ថវិប្បយុត្តធម៌

អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រាសចាកគន្ថៈ នូវខន្ធ២ ...ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ។ គន្ថសម្បយុត្តធម៌ អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវបដិឃៈ។ គន្ថសម្បយុត្តធម៌ អាស្រ័យនូវគន្ថសម្បយុត្តធម៌ផង នូវគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈផង នូវលោភៈផង នូវខន្ធ២ ...ខន្ធ៣ ...អាស្រ័យនូវខន្ធ១ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង នូវខន្ធ២...។ សេចក្តីបំប្រួញ។

[១១២] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ៦ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៩ ក្នុងឈានប្បច្ច័យ មានវារៈ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៦ ក្នុងវិគតប្បច្ច័យ មានវារៈ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១១៣] គន្ថវិប្បយុត្តធម៌ អាស្រ័យនូវគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលប្រាសចាកគន្ថៈ ជាអហេតុកៈ នូវខន្ធ២ ...អហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។

[១១៤] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៧។ បណ្ឌិតកាលចែករំលែក ក្នុងនបុរេជាតប្បច្ច័យ គប្បីធ្វើឲ្យជាអរូបជាបឋម រូបបណ្ឌិតបានក្នុងទីណា បណ្ឌិតគប្បីធ្វើក្នុងទីនោះ ក្នុងកាលជាខាងក្រោយឯបដិឃៈ មិនមានក្នុងអរូបទេ។ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១១៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បណ្ឌិតគប្បីរាប់យ៉ាងនេះឯង សេចក្តីបំប្រួញ ...ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១១៦] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអវិគតប្បច្ច័យ មានវារៈ១។ ឯសហជាតវារៈ បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ។

ឯសហជាតវារៈ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

## បច្ចយវារៈ

[១១៧] គន្ថសម្បយុត្តធម៌ ពឹងផ្អែកនឹងគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ គន្ថវិប្បយុត្តធម៌ ពឹងផ្អែកនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពឹងផ្អែកនឹងខន្ធ១ ដែលប្រាសចាកគន្ថៈ ...វត្ថុ ពឹងផ្អែកនឹងពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ នឹងមហាភូត១ ...ពួកខន្ធដែលប្រាសចាកគន្ថៈ ពឹងផ្អែកនឹងវត្ថុ។ គន្ថសម្បយុត្តធម៌

ពឹងផ្អែកនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងបដិឃៈ។ ពួកគន្ថសម្បយុត្តធម៌ក្តី ពួកគន្ថវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងបដិឃៈ ពួកទិដ្ឋិគតវិប្បយុត្តក្ខន្ធផង លោភៈផង ពឹងផ្អែកនឹងវត្ថុ ពួកខន្ធដែលប្រកបដោយទោមនស្សផង បដិឃៈផង ពឹងផ្អែកនឹងវត្ថុ។ គន្ថសម្បយុត្តធម៌ ពឹងផ្អែកនឹងគន្ថសម្បយុត្តធម៌ផង នឹងគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ផង នឹងវត្ថុផង ដែលប្រកបដោយគន្ថៈ នឹងខន្ធ២ ...ខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងវត្ថុផង នឹងលោភៈផង នឹងខន្ធ២ ...ខន្ធ៣ ...ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយទោមនស្សផង នឹងវត្ថុផង នឹងបដិឃៈផង នឹងខន្ធ២...។ គន្ថវិប្បយុត្តធម៌ ពឹងផ្អែកនឹងគន្ថសម្បយុត្តធម៌ផង នឹងគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកគន្ថសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងលោភៈផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយទោមនស្សផង នឹងបដិឃៈផង លោភៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងវត្ថុផង បដិឃៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយទោមនស្សផង នឹងវត្ថុផង។ ពួកគន្ថសម្បយុត្តធម៌ក្តី ពួកគន្ថវិប្បយុត្តធម៌ក្តី

ពឹងផ្អែកនឹងគន្ថសម្បយុត្តធម៌ផង នឹងគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយគន្ថៈផង នឹងវត្ថុផង នឹងខន្ធ២ ...ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកគន្ថសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងលោភៈផង នឹងខន្ធ២ ...ខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយទោមនស្សផង នឹងបដិឃៈផង នឹងខន្ធ២ ...ខន្ធ៣ផង លោភៈផង ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងវត្ថុផង នឹងខន្ធ២ ...ខន្ធ៣ផង បដិឃៈផង ពឹងផ្អែកនឹងខន្ធ១ ដែលប្រកបដោយទោមនស្សផង នឹងវត្ថុផង នឹងខន្ធ២...។ សេចក្តីបំប្រួញ។

[១១៨] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១១៩] គន្ថវិប្បយុត្តធម៌ ពឹងផ្អែកនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ដែលប្រាសចាកគន្ថៈ មិនមានហេតុ ... អហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកខន្ធដែលប្រាសចាកគន្ថៈ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង។ សេចក្តីបំប្រួញ។

[១២០] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣។

សេចក្តីបំប្រួញ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១២១] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ។

[១២២] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអវិគតប្បច្ច័យ មានវារៈ១។

និស្សយវារៈ ក៏ប្រហែលគ្នានឹងបដិច្ចវារៈដែរ។

**សំសដ្ឋវារៈ**

[១២៣] គន្ថសម្បយុត្តធម៌ ច្រឡំនឹងគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡំនឹងខន្ធ១ ដែលប្រកបដោយគន្ថៈ នឹងខន្ធ២...។ គន្ថវិប្បយុត្តធម៌ ច្រឡំនឹងគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺលោភៈ ច្រឡំនឹងពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ បដិឃៈ ច្រឡំនឹងពួកខន្ធ ដែលប្រកបដោយទោមនស្ស។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ច្រឡំនឹងគន្ថសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង លោភៈផង ច្រឡំនឹងខន្ធ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ នឹងខន្ធ២ ...ខន្ធ៣ផង បដិឃៈផង ច្រឡំនឹងខន្ធ១ ដែលប្រកបដោយទោមនស្ស នឹងខន្ធ២...។ គន្ថវិប្បយុត្តធម៌ ច្រឡំនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡំនឹងខន្ធ១ ដែលប្រាសចាកគន្ថៈ នឹងខន្ធ២ ...បដិសន្ធិ។ គន្ថសម្បយុត្តធម៌ ច្រឡំនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

គឺពួកសម្បយុត្តកក្ខន្ធ ប្រទ្បាំនឹងលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកសម្បយុត្តកក្ខន្ធ ប្រទ្បាំនឹងបដិឃៈ។ គន្ថវិប្បយុត្តធម៌ ប្រទ្បាំនឹងគន្ថសម្បយុត្តធម៌ផង នឹងគន្ថវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ប្រទ្បាំនឹងខន្ធ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នឹងលោភៈផង នឹងខន្ធ២ ...ខន្ធ៣ ប្រទ្បាំនឹងខន្ធ១ ដែលប្រកបដោយទោមនស្សផង នឹងបដិឃៈផង នឹងខន្ធ២...។ សេចក្តីបំប្រួញ។

[១២៤] ក្នុងហេតុប្បច្ច័យ មានវារៈ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ៦ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ៦។

[១២៥] គន្ថវិប្បយុត្តធម៌ ប្រទ្បាំនឹងគន្ថវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ (នឹងធម៌) ប្រាសចាកគន្ថៈ ជាអហេតុកៈ ...មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ប្រទ្បាំនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ។ សេចក្តីបំប្រួញ។

[១២៦] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៦ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦។

[១២៧] ក្នុងនអធិបតិប្បច្ច័យ មានវារៈ៦ ព្រោះហេតុប្បច្ច័យ ...ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦។

[១២៨] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១។

**បញ្ហាវារៈ**

[១២៩] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកគន្ថសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកគន្ថសម្បយុត្តហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយទោមនស្ស ជាបច្ច័យនៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយហេតុប្បច្ច័យ គឺពួកគន្ថសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយទោមនស្ស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកគន្ថវិប្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ លោភៈដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ គឺបដិសន្ធិ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺលោភៈ ដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។

គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយហេតុប្បច្ច័យ គឺលោភៈដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺហេតុដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង លោភៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយទោមនស្សផង បដិឃៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺហេតុដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង លោភៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយទោមនស្សផង បដិឃៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយហេតុប្បច្ច័យ គឺហេតុដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង លោភៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ហេតុដែលប្រកបដោយទោមនស្សផង បដិឃៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[១៣០] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកគន្ថសម្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថសម្បយុត្តក្ខន្ធ។ មូលទាំងឡាយ បណ្ឌិតត្រូវសួរក្នុងបទទាំង៣។ ពួកគន្ថវិប្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថសម្បយុត្តក្ខន្ធ។ ពួកខន្ធដែលប្រកបដោយលោភៈ

តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី កើតឡើង និងពួកខន្ធដែលប្រកបដោយទោមនស្សក្តី បដិឃៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថសម្បយុត្តក្ខន្ធ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល ...នូវឧបោសថកម្ម ...ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសល ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងកិរិយាស្រាវជ្រាវ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ រមែងពិចារណានូវពួកកិលេស ដែលប្រាសចាកគន្ថៈ ដែលខ្លួនលះបង់ហើយ ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងច្បាស់នូវពួកកិលេស ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ឃើញច្បាស់នូវចក្ខុ ...នូវវត្ថុ ...នូវពួកគន្ថវិប្បយុត្តក្ខន្ធផង នូវលោភៈផង នូវបដិឃៈផង តាមអនិច្ចលក្ខណៈ ...ត្រេកអរ រីករាយ គន្ថវិប្បយុត្តរាគៈ កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានចក្ខុជាដើមនោះ វិចិកិច្ឆា ...ឧទ្ធច្ចៈ ...ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកព្រមព្រៀង ដោយគន្ថវិប្បយុត្តចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកគន្ថវិប្បយុត្តក្ខន្ធ ជាបច្ច័យនៃកិរិយា ពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល (ឲ្យ) នូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ត្រេកអរ រីករាយ នឹងកុសលកម្មនោះ

គន្ថសម្បយុត្តរាគៈ កើតឡើង ព្រោះប្រារព្ធនូវគុណជាត មានទានជាដើមនោះ ទិដ្ឋិ ...ទោមនស្ស កើតឡើង។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ ...នូវវត្ថុ ...ពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ពួកខន្ធដែលប្រកបដោយទោមនស្សក្តី បដិឃៈក្តី ប្រារព្ធនូវពួកគន្ថវិប្បយុត្តក្ខន្ធផង នូវលោភៈផង នូវបដិឃៈផង ទើបកើតឡើង។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកគន្ថសម្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវពួកខន្ធ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកគន្ថវិប្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវពួកខន្ធ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ពួកខន្ធដែលប្រកបដោយទោមនស្សក្តី បដិឃៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវពួកខន្ធ ដែលប្រកបដោយទោមនស្សផង នូវបដិឃៈផង។

[១៣១] គន្ថសម្បយុត្តធម៌ ជាច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺពួកគន្ថសម្បយុត្តក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកគន្ថសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺគន្ថសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺលោភៈ ដែលប្រាសចាកទិដ្ឋិ កើតឡើង ព្រោះធ្វើនូវពួកគន្ថសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ

គឺគន្ថសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋារូប ដោយអធិបតិប្បច្ច័យ ទិដ្ឋិគតវិប្បយុត្តលោភសហគតាធិបតិ ជាបច្ច័យនៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ទោមនស្សសហគតាធិបតិ ជាបច្ច័យនៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង កើតឡើង ព្រោះធ្វើនូវពួកគន្ថសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺទិដ្ឋិគតវិប្បយុត្តលោភសហគតាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តក្ខន្ធផង នៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ទោមនស្សសហគតាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ពិចារណា ព្រោះធ្វើនូវកម្ម មានទានជាដើមនោះ ឲ្យជាទីគោរព ពិចារណា ព្រោះធ្វើ (នូវពួកកុសល) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ឲ្យជាទីគោរព ចេញអំពីឈាន ហើយធ្វើនូវឈាន ឲ្យជាទីគោរព ហើយពិចារណា ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយធ្វើនូវមគ្គ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវផល ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ...នូវវត្ថុ ...បុគ្គលធ្វើនូវពួកគន្ថវិប្បយុត្តក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ គន្ថវិប្បយុត្តរាគៈ កើតឡើង ព្រោះធ្វើនូវធម្មជាត មានចក្ខុជាដើមនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺគន្ថវិប្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង

ដោយអធិបតិប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន ពិចារណានូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកគន្ថវិប្បយុត្តក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព គន្ថសម្បយុត្តរាគៈ កើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវកម្ម មានទានជាដើមនោះ ឲ្យជាទីគោរព។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺនូវចក្ខុ... នូវវត្ថុ ...ទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី កើតឡើង ព្រោះធ្វើនូវពួកគន្ថវិប្បយុត្តក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺពួកគន្ថសម្បយុត្តក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព។ មូល បណ្ឌិតត្រូវសួរផងចុះ ទិដ្ឋិគតវិប្បយុត្តលោភៈ កើតឡើង ព្រោះធ្វើនូវពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី កើតឡើង ព្រោះធ្វើនូវពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នូវលោភៈផង ឲ្យជាទីគោរព។

[១៣២] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកគន្ថសម្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធមុនៗ ជាបច្ច័យនៃទិដ្ឋិគតវិប្បយុត្តលោភៈក្រោយៗ ដោយអនន្តរប្បច្ច័យ

ពួកទោមនស្សសហគតក្ខន្ធមុនៗ ជាបច្ច័យនៃបដិឃៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកគន្ថសម្បយុត្តក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្រោយៗផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធក្រោយៗផង នៃបដិឃៈផង ដោយអនន្តរប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺទិដ្ឋិគតវិប្បយុត្តលោភៈមុនៗ ជាបច្ច័យនៃទិដ្ឋិគតវិប្បយុត្តលោភៈក្រោយៗ ដោយអនន្តរប្បច្ច័យ ទោមនស្សសហគតបដិឃៈមុនៗ ជាបច្ច័យនៃបដិឃៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកគន្ថវិប្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកគន្ថវិប្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺទិដ្ឋិគតវិប្បយុត្តលោភៈមុនៗ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បដិឃៈមុនៗ ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអនន្តរប្បច្ច័យ គឺទិដ្ឋិគតវិប្បយុត្តលោភៈមុនៗ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្រោយៗផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ បដិឃៈមុនៗ ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធក្រោយៗផង នៃបដិឃៈផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ

ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយអនន្តរប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធមុនៗផង លោភៈផង ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធមុនៗក្តី បដិឃៈក្តី ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធមុនៗក្តី លោភៈក្តី ជាបច្ច័យនៃទិដ្ឋិគតវិប្បយុត្តលោភៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធមុនៗក្តី បដិឃៈក្តី ជាបច្ច័យនៃបដិឃៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី ពួកទោមនស្សសហគតក្ខន្ធក្តី បដិឃៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធមុនៗក្តី លោភៈក្តី ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្រោយៗផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធមុនៗក្តី បដិឃៈក្តី ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធក្រោយៗផង នៃបដិឃៈផង ដោយអនន្តរប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយសមនន្តរប្បច្ច័យ។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ។

[១៣៣] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកគន្ថសម្បយុត្តក្ខន្ធ ជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ឧបនិស្ស័យ៣យ៉ាង គឺពួកគន្ថសម្បយុត្តក្ខន្ធ

ជាបច្ច័យនៃពួកគន្ថវិប្បយុត្តក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ។ មូលបណ្ឌិតត្រូវសួរផងចុះ ឧបនិស្ស័យ៣យ៉ាង គឺពួកគន្ថសម្បយុត្តក្ខន្ធជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យនៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយឧបនិស្សយប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលឲ្យនូវទាន ព្រោះអាស្រ័យនូវសទ្ធា។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានៈ នូវសីល...។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិទុក្ខ រដូវ និងភោជន ...ឲ្យនូវទាន ព្រោះអាស្រ័យនូវសេនាសនៈ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ បញ្ញា រាគៈ។បេ។ សេចក្តីប្រាថ្នា សេនាសនៈ ជាបច្ច័យនៃសទ្ធា។បេ។ នៃបញ្ញា រាគៈ ទោសៈ មោហៈ មានៈ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលដំឡើងនូវមានៈ ព្រោះអាស្រ័យនូវសទ្ធា ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ នូវបញ្ញា រាគៈ។បេ។ មានៈ និងសេចក្តីប្រាថ្នា ...សម្លាប់នូវសត្វ ព្រោះអាស្រ័យនូវសេនាសនៈ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយឧបនិស្សយប្បច្ច័យ គឺ (ឧបនិស្ស័យ) ៣យ៉ាង គឺបុគ្គលដំឡើងនូវមានៈ ព្រោះអាស្រ័យនូវសទ្ធា នូវសីល...។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានៈ សេចក្តីប្រាថ្នា និងកាយិកសុខ ...សម្លាប់នូវសត្វ ព្រោះអាស្រ័យនូវសេនាសនៈ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ បញ្ញា រាគៈ ទោសៈ

មោហៈ មានះ សេចក្តីប្រាថ្នា សេនាសនៈ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយឧបនិស្សយប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី ពួកទោមនស្សសហគតក្ខន្ធក្តី បដិឃៈក្តី ជាបច្ច័យនៃពួកគន្ថវិប្បយុត្តក្ខន្ធផង នៃទិដ្ឋិគតវិប្បយុត្តលោភៈផង នៃបដិឃៈផង ដោយឧបនិស្សយប្បច្ច័យ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី ពួកទោមនស្សសហគតក្ខន្ធក្តី បដិឃៈក្តី ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយឧបនិស្សយប្បច្ច័យ។[១៣៤] គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គលឃើញនូវចក្ខុ ...នូវវត្ថុ តាមអនិច្ចលក្ខណៈ ...ត្រេកអរ រីករាយ គន្ថវិប្បយុត្តរាគៈ កើតឡើង ព្រោះប្រារព្ធនូវចក្ខុជាដើមនោះ វិចិកិច្ឆា ...ឧទ្ធច្ចៈ ...ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ (ជាបច្ច័យ) នៃពួកគន្ថវិប្បយុត្តក្ខន្ធផង នៃទិដ្ឋិគតវិប្បយុត្តលោភៈផង នៃបដិឃៈផង

ដោយបុរេជាតប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គលត្រេកអរ រីករាយនឹងចក្ខុ ...នឹងវត្ថុ គន្ថសម្បយុត្តរាគៈ កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានចក្ខុជាដើមនោះ ទិដ្ឋិ...។បេ។ ទោមនស្ស កើតឡើង។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធក្តី លោភៈក្តី ពួកទោមនស្សសហគតក្ខន្ធក្តី បដិឃៈក្តី កើតឡើង ព្រោះប្រារព្ធនូវចក្ខុ ...នូវវត្ថុ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយបុរេជាតប្បច្ច័យ។

[១៣៥] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ១។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ១។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ។

[១៣៦] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអាសេវនប្បច្ច័យ ប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ អាវជ្ជនៈក្តី វុដ្ឋានក្តី មិនមាន (ក្នុងទីនេះទេ)។

[១៣៧] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺគន្ថសម្បយុត្តចេតនា

ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ទិដ្ឋិគតវិប្បយុត្តលោភសហគតចេតនា ជាបច្ច័យនៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទោមនស្សសហគតចេតនា ជាបច្ច័យនៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកកន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយកម្មប្បច្ច័យ គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទិដ្ឋិគតវិប្បយុត្តលោភសហគតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទោមនស្សសហគតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបដិឃៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺគន្ថវិប្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺគន្ថវិប្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។

[១៣៨] គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។

[១៣៩] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអាហារប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ៦។

[១៤០] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ បណ្ឌិតត្រូវចែកផងចុះ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយវិប្បយុត្តប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សហជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ។ ឯបច្ឆាជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ។

[១៤១] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ បណ្ឌិតត្រូវចែកផងចុះ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺមានវារៈ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។ គន្ថវិប្បយុត្តធម៌

ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ បណ្ឌិតត្រូវចែកផងចុះ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ទោមនស្សសហគតបដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺបុគ្គលត្រេកអរ រីករាយ នឹងចក្ខុ ...នឹងវត្ថុ គន្ថសម្បយុត្តរាគៈ ...ទិដ្ឋិ ...ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវវត្ថុ មានចក្ខុជាដើមនោះ វត្ថុជាបច្ច័យនៃពួកគន្ថសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង កើតឡើង ព្រោះប្រារព្ធនូវចក្ខុ ...នូវវត្ថុ វត្ថុជាបច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយអត្ថិប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺគន្ថសម្បយុត្តក្ខន្ធ១ផង វត្ថុផង ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ១ផង លោភៈផង ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២ ...ទោមនស្សសហគតក្ខន្ធ១ផង បដិឃៈផង ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២...។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ

បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺពួកគន្ថសម្បយុត្តក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ សហជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ សហជាត គឺពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង វត្ថុផង ជាបច្ច័យនៃលោភៈ ដោយអត្ថិប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធផង វត្ថុផង ជាបច្ច័យនៃបដិឃៈ ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ថសម្បយុត្តក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ថសម្បយុត្តក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ១ផង លោភៈផង ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...សហជាត គឺទោមនស្សសហគតក្ខន្ធ១ផង បដិឃៈផង ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ១ផង វត្ថុផង ជាបច្ច័យនៃខន្ធ៣ផង នៃលោភៈផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...សហជាត គឺទោមនស្សសហគតក្ខន្ធ១ផង វត្ថុផង ជាបច្ច័យនៃខន្ធ៣ផង នៃបដិឃៈផង ដោយអត្ថិប្បច្ច័យ ខន្ធ២...។

[១៤២] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៤ ក្នុងឈានប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងវិប្បយុត្តប្បច្ច័យ មាវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៤៣] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ

ដោយបុរេជាតប្បច្ច័យ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[១៤៤] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[១៤៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ សេចក្តីបំប្រួញ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងននិស្សយប្បច្ច័យ មានវារៈ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៩ សេចក្តីបំប្រួញ ...ក្នុងនមគ្គប្បច្ច័យ មានវារៈ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ៩។

[១៤៦] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារផងចុះ។ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ គន្ថសម្បយុត្តទុកៈ។

## គន្ថគន្ថនិយទុកៈ

## បដិច្ចវារៈ

[១៤៧] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិវេសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកគន្ថៈ។ ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈផង ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈផង អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ។ បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងគន្ថទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ។

## បញ្ហាវារៈ

[១៤៨] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយហេតុប្បច្ច័យ គឺពួកគន្ថហេតុ ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ បញ្ហាទាំង៩ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះផងចុះ។

[១៤៩] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយអារម្មណប្បច្ច័យ គឺពួកគន្ថៈកើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ពិចារណានូវកម្ម មានទានជាដើមនោះ (នូវពួកកុសល) ដែលខ្លួនសន្សំហើយ

ក្នុងកាលមុន ...នូវឈាន ...ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ ពិចារណានូវវោទានៈ នូវពួកកិលេស ដែលខ្លួនលះបង់ហើយ ...ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលពុះពោរឡើងហើយ ក្នុងកាលមុន នូវចក្ខុ ...នូវវត្ថុ ...នូវពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ តាមអនិច្ចលក្ខណៈ ...ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ។ បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ។ ជាបច្ច័យនៃការស្រាវជ្រាវ ដោយអារម្មណប្បច្ច័យ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...បុគ្គលធ្វើនូវឧបោសថកម្ម ហើយត្រេកអរ រីករាយនឹងកុសលកម្មនោះ រាគៈកើតឡើង ទិដ្ឋិ ...វិចិកិច្ឆា ...ឧទ្ធច្ចៈ ...ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ (នូវពួកកុសល) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ចំពោះពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ រាគៈកើតឡើង ទិដ្ឋិ ...ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានឈានជាដើមនោះ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈផង នៃធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម... (នូវពួកកុសល) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញ អំពីឈាន នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ នឹងពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ ពួកគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានឈានជាដើមនោះ។ វារៈទាំង៣ ក្រៅពីនេះ បណ្ឌិតគប្បីឲ្យពិស្តារ ប្រារព្ធធ្វើយ៉ាងនេះផងចុះ។

លោកុត្តរៈ មិនមានក្នុងទុកៈនេះទេ តែបណ្ឌិតត្រូវកំណត់ថា គន្ថនិយៈ ប្រហែលគ្នានឹងគន្ថទុកៈដែរ មិនមានការធ្វើផ្សេងគ្នាទេ។ ក្នុងមគ្គប្បច្ច័យ បណ្ឌិត ត្រូវធ្វើឲ្យជាបញ្ហា៩។

ចប់ គន្ថគន្ថនិយទុកៈ។

**គន្ថគន្ថសម្បយុត្តទុកៈ**

**បដិច្ចវារៈ**

[១៥០] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិវេសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកគន្ថៈ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ នូវខន្ធ២...។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថៈ អាស្រ័យនូវពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី អាស្រ័យនូវធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកគន្ថៈផង អាស្រ័យនូវខន្ធ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ នូវខន្ធ២...។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថៈ អាស្រ័យនូវពួកគន្ថៈផង នូវពួកសម្បយុត្តក្ខន្ធផង។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង នូវពួកគន្ថៈផង នូវខន្ធ២...។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង អភិជ្ឈាកាយគន្ថៈផង អាស្រ័យនូវខន្ធ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង នូវសីលព្វតបរាមាសកាយគន្ថៈផង នូវខន្ធ២... បណ្ឌិតគប្បីចងឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។

[១៥១] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៥២] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ។ សេចក្តីបំប្រួញ។ នហេតុប្បច្ច័យ មិនមានក្នុងទីនេះទេ។

[១៥៣] ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩។

ការរាប់ទាំង២ ក្រៅពីនេះក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈយ៉ាងនេះដែរ។

**បញ្ហាវារៈ**

[១៥៤] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង

ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ។

[១៥៥] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺពួកគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកខន្ធជាគន្ថៈផង ជាគន្ថសម្បយុត្តផង កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកគន្ថៈកើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកគន្ថៈក្តី ពួកគន្ថសម្បយុត្តក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ។ បញ្ហាវារៈទាំង៣ក្រៅនេះ បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ។ ក្នុងអធិបតិប្បច្ច័យក្តី ក្នុងអនន្តរប្បច្ច័យក្តី ក្នុងឧបនិស្សយប្បច្ច័យក្តី

ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ។ ការចែក (ឲ្យផ្សេងពីនេះទៅទៀត មិនមានទេ)។

[១៥៦] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។ អរូបៈ ក៏មានបច្ច័យដែរ។ (បញ្ហាវារៈ) បីៗ នៃបច្ច័យមួយៗ បណ្ឌិតត្រូវធ្វើផងចុះ។ អារម្មណប្បច្ច័យក្តី សហជាតប្បច្ច័យក្តី ឧបនិស្សយប្បច្ច័យក្តី បណ្ឌិតត្រូវបង្វិលក្នុងវារៈទាំង៩ផងចុះ។ បច្ច័យទាំងអស់ បណ្ឌិតត្រូវធ្វើក្នុងបញ្ហាវារៈយ៉ាងនេះផងចុះ។

ចប់ គន្ថគន្ថសម្បយុត្តទុកៈ។

## គន្ថវិប្បយុត្តគន្ថនិយទុកៈ

### បដិច្ចវារៈ

[១៥៧] គន្ថវិប្បយុត្តធម៌ (ធម៌ដែលប្រាសចាកគន្ថៈ) និងគន្ថនិយធម៌ (ធម៌ដែលគួរដល់គន្ថៈ) អាស្រ័យនូវគន្ថវិប្បយុត្តធម៌ និងគន្ថនិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ដែលជាគន្ថវិប្បយុត្ត និងជាគន្ថនិយៈ នូវខន្ធ២ ...ក្នុងបដិសន្ធិក្ខណៈ មហាភូត១...។បេ។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈ យ៉ាងណា បណ្ឌិតត្រូវឲ្យពិស្តារ យ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ។

ចប់ គន្ថវិប្បយុត្តគន្ថនិយទុកៈ។

## ឱឃយោគគោច្ឆកទុកៈ

## បដិច្ចវារៈ

[១៥៨] អាស្រ័យនូវឱឃធម៌ ...យោគធម៌ អាស្រ័យនូវយោគធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ។ ឯគោច្ឆកៈទាំងពីរ (នេះ) ដូចគ្នានឹងអាសវគោច្ឆកៈដែរ មិនមានការធ្វើផ្សេងៗទេ។

ចប់ ឱឃយោគគោច្ឆកទុកៈ។

## នីវរណទុកៈ

## បដិច្ចវារៈ

[១៥៩] នីវរណធម៌ (ធម៌ជាគ្រឿងរារាំង) អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ។ នោនីវរណធម៌ (ធម៌មិនមែនជាគ្រឿងរារាំង) អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកនីវរណៈ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈផង ឧទ្ធច្ចនីវរណៈផង អវិជ្ជានីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវកាមច្ឆន្ទនីវរណៈ បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ និងចិត្តសមុដ្ឋានរូប អាស្រ័យនូវនោនីវរណក្ខន្ធ១ បដិសន្ធិ។ នីវរណធម៌

អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ អាស្រ័យនូវពួកនោនីវរណក្ខន្ធ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកនីវរណៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ១ នូវខន្ធ២...។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថិនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង (បណ្ឌិតត្រូវធ្វើ) ឲ្យជាចក្កៈផងចុះ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ១ផង នូវនីវរណៈផង នូវខន្ធ២...។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ថិនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវនោនីវរណក្ខន្ធ១ផង នូវកាមច្ឆន្ទនីវរណៈផង នូវខន្ធ២... (បណ្ឌិតត្រូវធ្វើ) ឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។

[១៦០] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៦១] នីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ១ ជាអហេតុកៈ នូវខន្ធ២ ...តាំងពីអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ។ នីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង

ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង។

[១៦២] នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនោនីវរណក្ខន្ធ រហូតដល់ពួកអសញ្ញសត្វ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង។ សេចក្តីបំប្រួញ។ ព្រោះនអធិបតិប្បច្ច័យ ព្រោះនអនន្តរប្បច្ច័យ ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ។

[១៦៣] នីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ក្នុងអរូប ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ក្នុងអរូប ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ ក្នុងអរូប អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ ក្នុងអរូប។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកនីវរណៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈ ក្នុងអរូប។ បញ្ហាដ៏សេសសល់ទាំងអស់ បណ្ឌិតត្រូវឲ្យពិស្តារផងចុះ អរូបទី១ បណ្ឌិតត្រូវធ្វើ (ឲ្យដូចគ្នាផងចុះ) រូប បណ្ឌិតកាន់យក ដូចជាបទខាងក្រោយ។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង

នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អាស្រ័យនូវពួកនោនីវរណក្ខន្ធផង នូវកាមច្ឆន្ទនីវរណៈផង ក្នុងអរូប (បណ្ឌិតត្រូវធ្វើឲ្យ) ជាចក្កៈផងចុះ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវនោនីវរណក្ខន្ធ១ផង នូវពួកនីវរណៈផង ក្នុងអរូប នូវខន្ធ២ ...ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកមហាភូតផង។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ៣ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវនោនីវរណក្ខន្ធ១ផង នូវកាមច្ឆន្ទនីវរណៈផង ក្នុងអរូប (បណ្ឌិតត្រូវធ្វើ) ឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។

[១៦៤] ក្នុងនហេតុប្បច្ច័យ មានវារៈ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១៦៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩។ សេចក្តីបំប្រួញ។

[១៦៦] ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះនហេតុប្បច្ច័យ ...ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ៤។

ឯសហជាតវារៈ បណ្ឌិតត្រូវធ្វើឲ្យពិស្តារយ៉ាងនេះផងចុះ។

**បច្ចយវារៈ**

[១៦៧] នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣។ នោនីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ១ រហូតដល់ពួកអជ្ឈត្តិកមហាភូត ពួកនោនីវរណក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ នីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ ពឹងផ្អែកនឹងពួកនោនីវរណក្ខន្ធ ពួកនីវរណៈ ពឹងផ្អែកនឹងវត្ថុ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកនីវរណៈផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ១ នឹងខន្ធ២ ...ពួកនីវរណៈក្តី ពួកសសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ។ នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ថីនមិទ្ធនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងវត្ថុផង បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ។ នោនីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ១ផង នឹងពួកនីវរណៈផង នឹងខន្ធ២ ...ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងពួកនីវរណៈផង នឹងវត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណៈផង នឹងពួកមហាភូតផង។ នីវរណធម៌ក្តី

នោនីវរណធម៌ក្តី ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងនោនីវរណក្ខន្ធ១ផង នឹងកាមច្ឆន្ទនីវរណៈផង នឹងខន្ធ២ ...បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ និងពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងវត្ថុផង បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។

[១៦៨] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៦៩] នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈ។ នោនីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ១ ជាអហេតុកៈ នឹងខន្ធ២ ...រហូតដល់ពួកអសញ្ញសត្វ ពួកនោនីវរណក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ។ នីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អវិជ្ជានីវរណៈ ពឹងផ្អែកនឹងវត្ថុ។ នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈផង នឹងវត្ថុផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈផង នឹងវត្ថុផង។ សេចក្តីបំប្រួញ។

[១៧០] ក្នុងនហេតុប្បច្ច័យ មានវារៈ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១៧១] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩។ សេចក្តីបំប្រួញ។

[១៧២] ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះនហេតុប្បច្ច័យ ...ក្នុងអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ៤។

## សំសដ្ឋវារៈ

[១៧៣] នីវរណធម៌ លាយឡំនឹងនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ លាយឡំនឹងកាមច្ឆន្ទនីវរណៈ បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ នីវរណៈទាំងអស់ បណ្ឌិតត្រូវឲ្យពិស្តារផងចុះ។

[១៧៤] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៧៥] នីវរណធម៌ លាយឡំនឹងនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ លាយឡំនឹងវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ លាយឡំនឹងឧទ្ធច្ចនីវរណៈ។ សេចក្តីបំប្រួញ។

[១៧៦] ក្នុងនហេតុប្បច្ច័យ មានវារៈ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩។

ការរាប់ពីរយ៉ាង ដទៃពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតត្រូវធ្វើយ៉ាងនេះផងចុះ។

**បញ្ហាវារៈ**

[១៧៧] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនោនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ បដិសន្ធិ។

[១៧៨] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនោនីវរណក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ពិចារណានូវកុសលកម្មនោះ ត្រេកអរ រីករាយ នឹងកុសលកម្មនោះ

ទិដ្ឋិកើតឡើង ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...បុគ្គលចេញអំពីឈាន នូវឈាន ...ពួកព្រះអរិយៈ ចេញអំពីមគ្គ នូវមគ្គ ...នូវផល ...នូវនិព្វាន ...និព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកនោនីវរណក្កិលេល ដែលខ្លួនលះបង់ហើយ នូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ... (នូវកងអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ នូវពួកនោនីវរណក្ខន្ធ ថាមិនទៀង ...ទោមនស្សកើតឡើង បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គល អ្នកប្រកបដោយនោនីវរណចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកនោនីវរណក្ខន្ធ ជាបច្ច័យនៃកិរិយាពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ... (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...នូវពួកនោនីវរណក្ខន្ធ ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិ ...វិចិកិច្ឆា ...ឧទ្ធច្ចៈ ...ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ... (នូវពួកអំពី) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...នូវនោនីវរណក្ខន្ធ ត្រេកអរ រីករាយ ពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។

នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺវារៈ៣ បណ្ឌិតគប្បីប្រារព្ធធ្វើផងចុះ។

[១៧៩] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺពួកនីវរណៈ កើតឡើង ព្រោះធ្វើនូវពួកនីវរណៈឲ្យជាទីគោរព។ វារៈទាំង៣ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយធ្វើនូវអំពើនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះឲ្យជាទីគោរព នូវពួកអំពើ ដែលខ្លួនសន្សំហើយក្នុងកាលមុន ...អំពីឈាន ...ពួកព្រះអរិយៈចេញអំពីមគ្គ នូវមគ្គ ...នូវផល ...នូវនិព្វាន ...និព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺនោនីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺនោនីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយអធិបតិប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន

...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវហេតុនោះឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺនោនីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ វារៈទាំង៣ គឺអារម្មណាធិបតិហ្នឹងឯង។

[១៨០] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកនីវរណៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតគប្បីសួរផងចុះ។ ពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ ពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកនីវរណៈ ដោយអនន្តរប្បច្ច័យ។ ពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកនីវរណក្ខន្ធផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណក្ខន្ធមុនៗផង

ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ ពួកនីវរណៈមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកនីវរណក្ខន្ធក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ ពួកនីវរណៈមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនីវរណៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ។

[១៨១] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកនីវរណៈ មានវារៈ៣។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន នូវសីល ...នូវឧបោសថកម្ម ...ញុំាងឈានឲ្យកើតឡើង ញុំាងវិបស្សនា ...ញុំាងមគ្គ ...ញុំាងអភិញ្ញា ...ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល។បេ។ នូវបញ្ញា ...នូវរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ និងកាយិកទុក្ខ ...អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា។បេ។ នៃបញ្ញា នៃរាគៈ។បេ។ នៃសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ

ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ។បេ។ ជាបច្ច័យនៃសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយតាំងឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃពួកនីវរណក្ខន្ធផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ។ នីវរណធម៌ក្ដី នោនីវរណធម៌ក្ដី ជាបច្ច័យនៃនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកនីវរណៈ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ៣។

[១៨២] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...នូវវត្ថុ ថាមិនទៀង ...ទោមនស្សកើតឡើង។ មានវារៈ៣។ បុរេជាតប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ បណ្ឌិតគប្បីចែក (តាមវារៈ) នៃកុសល និងអកុសលផងចុះ។

[១៨៣] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ គឺមានវារៈ៩។

[១៨៤] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺនោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺនោនីវរណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។

មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ នោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយកម្មប្បច្ច័យ។ នោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។

[១៨៥] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ។

[១៨៦] នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ ប្រស្នាទាំង៤ដ៏សេស បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

[១៨៧] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ គឺកាមច្ឆន្ទនីវរណៈ ជាបច្ច័យនៃថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ដោយអត្ថិប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ ក្នុងនីវរណមូល មានវារៈ៣យ៉ាងនេះឯង។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សេចក្តីបំប្រួញ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សេចក្តីបំប្រួញ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺកាមច្ឆន្ទនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ដោយអត្ថិប្បច្ច័យ កាមច្ឆន្ទនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃថីនមិទ្ធនីវរណៈ និងអវិជ្ជានីវរណៈ

ដោយអត្ថិប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺខន្ធ១ ជានោនីវរណៈផង ពួកនីវរណៈផង ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...ពួកនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃនោនីវរណក្ខន្ធ ដោយអត្ថិប្បច្ច័យ ពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកនីវរណៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ ជានោនីវរណៈផង កាមច្ឆន្ទនីវរណៈផង ជាច្ច័យនៃខន្ធ៣ផង នៃថីនមិទ្ធនីវរណៈផង នៃឧទ្ធច្ចនីវរណៈផង នៃអវិជ្ជានីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...កាមច្ឆន្ទនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃថីនមិទ្ធនីវរណៈផង នៃឧទ្ធច្ចនីវរណៈផង នៃអវិជ្ជានីវរណៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ (បណ្ឌិតគប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។

[១៨៨] ក្នុងហេតុប្បច្ច័យ មានវារៈ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣

ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[១៨៩] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ

ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[១៩០] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[១៩១] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៤។ សេចក្តីបំប្រួញ។ ...ក្នុងនមគ្គប្បច្ច័យ មានវារៈ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ៤។

[១៩២] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារចុះ។ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ នីវរណទុកៈ។

## នីវរណិយទុកៈ

## បដិច្ចវារៈ

[១៩៣] នីវរណិយធម៌ អាស្រ័យនូវនីវរណិយធម៌ ទើបកើតឡើង...។ នីវរណិយទុកៈ យ៉ាងណា លោកិយទុកៈ បណ្ឌិតគប្បីធ្វើយ៉ាងនោះចុះ មិនមានការធ្វើផ្សេងគ្នាឡើយ។

ការប្រកបដោយកាមច្ឆន្ទៈពីរលើក ការប្រកបដោយបដិឃៈ បួនលើក ឧទ្ធច្ចៈ១ វិចិកិច្ឆា១ ទាំងពីរនុ៎ះ មានការប្រកបមួយលើកៗ ការប្រកបនូវពួកនីវរណៈ ដោយពួកនីវរណៈ មានប្រការ៨ (យ៉ាងនេះឯង)។

មាតិកានៃនីវរណទុកៈ លោកបានធ្វើទុកក្នុងទីនេះ។

ចប់នីវរណិយទុកៈ

## នីវរណសម្បយុត្តទុកៈ

## បដិច្ចវារៈ

[១៩៤] នីវរណសម្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្ត នូវខន្ធ២...។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណសម្បយុត្តក្ខន្ធ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្តផង នូវចិត្តសមុដ្ឋានរូបផង នូវខន្ធ២...។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ...ជានីវរណវិប្បយុត្ត នូវខន្ធ២ ...បដិសន្ធិ មានដរាបដល់ពួកមហាភូតខាងក្នុង។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ផង នូវនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង។ សេចក្តីបំប្រួញ។

[១៩៥] ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ២ ក្នុងវិគតប្បច្ច័យ មានវារៈ២ ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

[១៩៦] នីវរណសម្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺជានីវរណវិប្បយុត្ត ជាអហេតុកៈ ...ដរាបដល់ពួកអសញ្ញសត្វ។ សេចក្តីបំប្រួញ។

[១៩៧] ក្នុងនហេតុប្បច្ច័យ មានវារៈ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១៩៨] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[១៩៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ព្រោះនហេតុប្បច្ច័យ។បេ។ ...ក្នុងមគ្គប្បច្ច័យ មានវារៈ១។បេ។ ...ក្នុងអវិគតប្បច្ច័យ មានវារៈ២។

ឯសហជាតវារៈ បណ្ឌិតត្រូវធ្វើឲ្យជាវារៈ១ចុះ។

## បច្ចយវារៈ

[២០០] នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ ជានីវរណវិប្បយុត្ត នឹងខន្ធ២ ...បដិសន្ធិ ពួកនីវរណវិប្បយុត្តក្ខន្ធ ពឹងផ្អែកនឹងមហាភូត១ នឹងវត្ថុ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ពួកនីវរណសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ជានីវរណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ២...។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងខន្ធ១ ជានីវរណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ២ ...ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង។ សេចក្តីបំប្រួញ។

[២០១] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៤។បេ។ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[២០២] នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ ជាអហេតុកៈ ជានីវរណវិប្បយុត្ត ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ

ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកនីវរណវិប្បយុត្តក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង។ សេចក្តីបំប្រួញ។

[២០៣] ក្នុងនហេតុប្បច្ច័យ មានវារៈ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣។បេ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

ការរាប់វារៈទាំង២ក្រៅពីនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

**សំសដ្ឋវារៈ**

[២០៤] នីវរណសម្បយុត្តធម៌ លាយឡំនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ។

[២០៥] ក្នុងហេតុប្បច្ច័យ មានវារៈ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ២ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ២។

[២០៦] នីវរណសម្បយុត្តធម៌ លាយឡំនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ លាយឡំនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ លាយឡំនឹងនីវរណវិប្បយុត្តធម៌...។

[២០៧] ក្នុងនហេតុប្បច្ច័យ មានវារៈ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ២ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ២ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២។

ការរាប់វារៈទាំង២ក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

**បញ្ហាវារៈ**

[២០៨] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ។ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណវិប្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺជាបដិសន្ធិ។

[២០៩] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ត្រេកអរ រីករាយ ចំពោះទិដ្ឋិ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ វិចិកិច្ឆា ទិដ្ឋិ ឧទ្ធច្ចៈ ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវវិចិកិច្ឆា ឧទ្ធច្ចៈកើតឡើង ព្រោះប្រារព្ធនូវឧទ្ធច្ចៈ ទិដ្ឋិ ...វិចិកិច្ឆា កើតឡើង ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវទោមនស្ស ទិដ្ឋិ ...វិចិកិច្ឆា ...ឧទ្ធច្ចៈ កើតឡើង។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ជានីវរណសម្បយុត្ត ដែលខ្លួនលះបង់ហើយ ពិចារណានូវពួកកិលេស

ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ឃើញនូវពួកនីវរណសម្បយុត្តក្ខន្ធ ថាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងនូវចិត្តនៃបុគ្គលអ្នកប្រកបដោយនីវរណសម្បយុត្តចិត្ត ដោយចេតោបរិយញ្ញាណ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ពិចារណានូវហេតុនោះ (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន នូវឈាន ...ពួកព្រះអរិយៈ ចេញអំពីមគ្គ នូវមគ្គ ...ពិចារណានូវផល នូវព្រះនិព្វាន ... ព្រះនិព្វាន ជាបច្ច័យនៃកិរិយាពិចារណា នូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ ...ឃើញច្បាស់នូវវត្ថុ នូវពួកនីវរណវិប្បយុត្តក្ខន្ធ ថាមិនទៀង ជាទុក្ខ ជាអនត្តា ឃើញនូវរូបដោយទិព្វចក្ខុ ដរាបអំពីអាវជ្ជនៈ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ចំពោះពួកនីវរណវិប្បយុត្តក្ខន្ធ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។

[២១០] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវរាគៈ ឲ្យជាទីគោរព រាគៈ ទិដ្ឋិកើតឡើង ព្រោះធ្វើនូវរាគៈនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺនីវរណសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអធិបតិប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺនីវរណសម្បយុត្តាធិបតិ

ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ។ មូល បណ្ឌិតគប្បីសួរផងចុះ នីវរណសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ធ្វើនូវហេតុនោះ ឲ្យជាទីគោរព ហើយពិចារណា (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន នូវឈាន ...ពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ...នូវផល ...នូវព្រះនិព្វាន ...ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ។ ឯសហជាតាធិបតិ គឺនីវរណវិប្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺនូវទាន...។បេ។ ក្នុងកាលមុន ...នូវឈាន ...នូវចក្ខុ ...នូវវត្ថុ ...ធ្វើនូវពួកនីវរណវិប្បយុត្តក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព។

[២១១] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណសម្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ (ខន្ធ៣) មុនៗ មិនមានក្នុងទីនេះទេ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណវិប្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណវិប្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ គឺអនុលោមញ្ញាណ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ

គឺអាវជ្ជនៈ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយសមនន្តរប្បច្ច័យ។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ។

[២១២] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ នូវទោសៈ ...នូវមោហៈ មានះ និងទិដ្ឋិ ...អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ រាគៈ។បេ។ សេចក្តីប្រាថ្នា (ជាបច្ច័យ) នៃរាគៈ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ហើយឲ្យនូវទាន នូវសីល ...នូវឧបោសថកម្ម ញុំាងឈាន វិបស្សនា មគ្គ និងអភិញ្ញា ...ញុំាងសមាបត្តិឲ្យកើងឡើង នូវទោសៈ ...អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង រាគៈ។បេ។ សេចក្តីប្រាថ្នា (ជាបច្ច័យ) នៃសទ្ធា។បេ។ ជាបច្ច័យនៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន នូវសីល...។បេ។ ញុំាងមគ្គ ...ញុំាងអភិញ្ញា ...ញុំាងសមាបត្តិឲ្យកើតឡើង នូវសីល...។បេ។ នូវបញ្ញា...។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង សទ្ធា។បេ។ សេនាសនៈ (ជាបច្ច័យ) នៃសទ្ធា។បេ។ ជាបច្ច័យនៃបញ្ញា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នីវរណវិប្បយុត្តធម៌

ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ នូវបញ្ញា ...កាយិកៈ...។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។

[២១៣] នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ ជាអនត្តា ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនីវរណវិប្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈ ទោសៈ មោហៈ (កើតឡើង) ព្រោះប្រារព្ធនូវហេតុនោះ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ។

[២១៤] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ២។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ គឺមានវារៈ២។

[២១៥] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ បានដល់សហជាត និងនានាខណិកៈ។

សហជាត គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ នីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សេចក្តីបំប្រួញ។ ជាបច្ច័យ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។

[២១៦] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអាហារប្បច្ច័យ។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ២។

[២១៧] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ។

[២១៨] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺខន្ធ១ ជានីវរណសម្បយុត្ត ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សហជាត គឺពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺខន្ធ១ ជានីវរណសម្បយុត្ត

ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ជាបច្ច័យនៃខន្ធ២ ដោយអត្ថិប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់បុរេជាត គឺបុគ្គល នូវចក្ខុ ...ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ វត្ថុ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអត្ថិប្បច្ច័យ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺខន្ធ១ ជានីវរណសម្បយុត្តផង វត្ថុផង ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២ផង វត្ថុផង ជាបច្ច័យនៃខន្ធ២ ដោយអត្ថិប្បច្ច័យ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺពួកនីវរណសម្បយុត្តក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺពួកនីវរណសម្បយុត្តក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកនីវរណសម្បយុត្តក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។

[២១៩] ក្នុងហេតុប្បច្ច័យ មានវារៈ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ

មានវារៈ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៤ ក្នុងឈានប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងវិគតប្បច្ច័យ មានវារៈ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ៧។

[២២០] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយសហជាតប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។

[២២១] ក្នុងនហេតុប្បច្ច័យ មានវារៈ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៧

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងននិស្សយប្បច្ច័យ មានវារៈ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៤។

[២២២] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ៤។

[២២៣] ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ការរាប់ជាអនុលោម បណ្ឌិតគប្បីធ្វើចុះ ក្នុងអវិគតប្បច្ច័យ មានវារៈ៧។

ចប់ នីវរណសម្បយុត្តទុកៈ។

## នីវរណនីវរណិយទុកៈ

### បដិច្ចវារៈ

[២២៤] ធម៌ជានីវរណៈ និងជានីវរណិយៈ អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ។ ការរាប់ទាំងអស់ បណ្ឌិតគប្បីចែកយ៉ាងនេះចុះ។ ប្រហែលគ្នានឹងនីវរណទុកៈដែរ ឥតមានការធ្វើឲ្យផ្សេងគ្នាឡើយ។

### បញ្ហាវារៈ

[២២៥] ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ។ ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណិយៈ និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈផង នៃធម៌ជានីវរណិយៈ និងជានោនីវរណៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណិយៈ និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មានបដិសន្ធិ។

[២២៦] ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណិយៈ និងជានោនីវរណៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវឧបោសថកម្មនោះ ត្រេកអរ រីករាយ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន

...អំពីឈាន ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ នូវវោទានៈ ...នូវពួកកិលេស ដែលខ្លួនលះបង់ហើយ ...នូវពួកកិលេសដែលខ្លួនសង្កត់សង្កិនហើយ ...នូវពួកកិលេស ដែលខ្លួនដកឡើងព្រមហើយ ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ ...នូវពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ ថាមិនទៀង ...ឃើញច្បាស់ ត្រេកអរ រីករាយ។បេ។ ទោមនស្ស ...ដោយទិព្វចក្ខុ ...ការនឹករំពឹង (មាន) ត្រឹមណា បណ្ឌិតត្រូវធ្វើត្រឹមណោះ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ... (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ចំពោះពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។ ធម៌ជានីវរណិយៈ និងជានោនីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈផង នៃធម៌ជានីវរណិយៈ និងជានោនីវរណៈផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ... (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ចំពោះពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។ បណ្ឌិតគប្បីធ្វើនូវវារៈទាំង៣ដទៃយ៉ាងនេះចុះ។

អធិបតិប្បច្ច័យប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ។ សូម្បីបុរេជាតប្បច្ច័យក៏ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ។ បណ្ឌិតមិនត្រូវធ្វើនូវលោកុត្តរៈ ក្នុងឧបនិស្សយប្បច្ច័យឡើយ។ សេចក្តីបំប្រួញ។ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ។ នីវរណទុកៈ យ៉ាងណា បណ្ឌិត គប្បីពិចារណា ហើយធ្វើយ៉ាងនោះចុះ។

ចប់ នីវរណនីវរណិយទុកៈ

**នីវរណនីវរណសម្បយុត្តទុកៈ**

**បដិច្ចវារៈ**

[២២៧] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ នីវរណៈទាំងអស់ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកនីវរណៈ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ និងពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ បណ្ឌិតគប្បីធ្វើឲ្យជាចក្កផងចុះ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈ នូវខន្ធ២...។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ អាស្រ័យនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ពួកនីវរណៈផង អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈ នូវខន្ធ២...។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង បណ្ឌិត (គប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណៈ

និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈផង នូវពួកនីវរណៈផង នូវខន្ធ២...។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ជាថិនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងជាអវិជ្ជានីវរណៈ អាស្រ័យនូវខន្ធ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈផង នូវកាមច្ឆន្ទនីវរណៈផង នូវខន្ធ២ ...បណ្ឌិត (គប្បីធ្វើ) ឲ្យជាចក្កៈផងចុះ។ សេចក្តីបំប្រួញ។

[២២៨] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងអាហារប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[២២៩] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង។ សេចក្តីបំប្រួញ។ [២៣០] ក្នុងនហេតុប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩

ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩។

[២៣១] ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ...ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៩។

[២៣២] ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ ...ក្នុងអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ៣។ សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈយ៉ាងនេះដែរ មិនមានការធ្វើឲ្យផ្សេងគ្នាទេ។

**បញ្ហាវារៈ**

[២៣៣] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកនីវរណសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយហេតុប្បច្ច័យ។

[២៣៤] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ

ពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ ពួកនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ។ ពួកនីវរណក្តី ពួកសម្បយុត្តកក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺមានវារៈ៣។

[២៣៥] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ។ វារៈទាំង៣ បានដល់គរុការម្មណ៍ហ្នឹងឯង។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ។ ពួកនីវរណៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ឲ្យជាទីគោរព សហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ

ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយអធិបតិប្បច្ច័យ។ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ឲ្យជាទីគោរព សហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយអធិបតិប្បច្ច័យ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី ជាបច្ច័យនៃធម៌ ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ។ គឺមានវារៈ៣។

[២៣៦] ជាបច្ច័យ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈក្តី វុដ្ឋានៈក្តី មិនមានទេ (ពួកខន្ធ) មុនៗ បណ្ឌិតគប្បីធ្វើក្នុងបច្ច័យទាំងអស់ចុះ។ ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ មានវារៈ៩ ដូចគ្នានឹងអារម្មណប្បច្ច័យដែរ វិភង្គ មិនមានទេ។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ។

[២៣៧] ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយកម្មប្បច្ច័យ គឺចេតនា ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរចុះ។ ចេតនា ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយកម្មប្បច្ច័យ។ ចេតនា ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយកម្មប្បច្ច័យ។

[២៣៨] ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអាហារប្បច្ច័យ គឺមានវារៈ៣។

ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយឈានប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ មានវារៈ៣។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយវិគតប្បច្ច័យ មានវារៈ៩។ ជាបច្ច័យ ដោយអវិគតប្បច្ច័យ មានវារៈ៩។

[២៣៩] ក្នុងហេតុប្បច្ច័យ មានវារៈ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[២៤០] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ វារៈទាំង៩ បណ្ឌិតគប្បីប្រែត្រឡប់ក្នុងបទទាំង៣យ៉ាងនេះចុះ។

[២៤១] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[២៤២] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៤៣] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩។ អនុលោមមាតិកា បណ្ឌិតត្រូវធ្វើចុះ។ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

ចប់ នីវរណនីវរណសម្បយុត្តទុកៈ។

## នីវរណវិប្បយុត្តនីវរណិយទុកៈ

### បដិច្ចវារៈ

[២៤៤] ធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ អាស្រ័យនូវធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ជានីវរណវិប្បយុត្ត និងជានីវរណិយៈ នូវខន្ធ២ ...បដិសន្ធិ។ សេចក្តីបំប្រួញ។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណា បណ្ឌិតគប្បីធ្វើយ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាឡើយ។

ចប់ នីវរណវិប្បយុត្តនីវរណិយទុកៈ

## បរាមាសទុកៈ

### បដិច្ចវារៈ

[២៤៥] នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមាសៈ។ នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាបរាមាសៈ នូវខន្ធ២ ...បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ពួកមហាភូត។ បរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបរាមាសៈ អាស្រ័យនូវពួកនោបរាមាសក្ខន្ធ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង បរាមាសៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ មិនមែនជាបរាមាសៈ នូវខន្ធ២...។ នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ផង

នូវនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ១ មិនមែនជាបរាមាសៈផង នូវបរាមាសៈផង នូវខន្ធ២...។

[២៤៦] ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

[២៤៧] នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ១ ជាអហេតុកៈ មិនមែនជាបរាមាសៈ នូវខន្ធ២ ...អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។

[២៤៨] នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវបរាមាសៈ។ នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ដរាបដល់ពួកអសញ្ញសត្វ អាស្រ័យនូវពួកខន្ធមិនមែនជាបរាមាសៈ។ នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ផង នូវនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវបរាមាសៈផង នូវពួកសម្បយុត្តកក្ខន្ធផង។

[២៤៩] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥

ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។[២៥០] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៥១] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអនន្តរប្បច្ច័យ មានវារៈ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១។ ឯសហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ។

**បច្ចយវារៈ**

[២៥២] នោបរាមាសធម៌ ពឹងផ្អែកនឹងបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងបរាមាសៈ។ នោបរាមាសធម៌ ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាបរាមាសៈ នឹងខន្ធ២ ...បដិសន្ធិ ដរាបដល់ពួកមហាភូតខាងក្នុង ពួកនោបរាមាសក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ បរាមាសធម៌ ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបរាមាសៈ ពឹងផ្អែកនឹងពួកនោបរាមាសក្ខន្ធ បរាមាសៈ ពឹងផ្អែកនឹងវត្ថុ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង បរាមាសៈផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាបរាមាសៈ នឹងខន្ធ២ ...បរាមាសៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ។ នោបរាមាសធម៌

ពឹងផ្អែកនឹងបរាមាសធម៌ផង នឹងនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ១ មិនមែនជាបរាមាសៈផង នឹងបរាមាសៈផង នឹងខន្ធ២ ...ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងបរាមាសៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងបរាមាសៈផង នឹងពួកមហាភូតផង ពួកខន្ធមិនមែនជាបរាមាសៈ ពឹងផ្អែកនឹងបរាមាសៈផង និងវត្ថុផង។ សេចក្តីបំប្រួញ។

[២៥៣] ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

[២៥៤] នោបរាមាសធម៌ ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ១ មិនមែនជាបរាមាសៈ ជាអហេតុកៈ នឹងខន្ធ២ ...អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកខន្ធមិនមែនជាបរាមាសៈ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង។ សេចក្តីបំប្រួញ។

[២៥៥] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣។បេ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៥ នកម្មប្បច្ច័យ មានវារៈ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣

ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៥៦] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥។

បណ្ឌិតគប្បីធ្វើក្នុងបច្ច័យទាំងអស់យ៉ាងនេះចុះ។

[២៥៧] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអវិគតប្បច្ច័យ មានវារៈ១។

និស្សយវារៈ ប្រហែលគ្នានឹងបច្ចយវារៈដែរ។

**សំសដ្ឋវារៈ**

[២៥៨] នោបរាមាសធម៌ លាយឡំនឹងបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ លាយឡំនឹងបរាមាសៈ។ បញ្ហា៥ ក្នុងអរូប បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ។

សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

**បញ្ហាវារៈ**

[២៥៩] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាបរាមាសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាបរាមាសៈ ជាបច្ច័យនៃបរាមាសៈ ដោយហេតុប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាបរាមាសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបរាមាសៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[២៦០] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺបរាមាសៈ ប្រារព្ធនូវបរាមាសៈ ទើបកើតឡើង។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ ពួកខន្ធមិនមែនជាបរាមាសៈ ប្រារព្ធនូវបរាមាសៈ

ទើបកើតឡើង។ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវបរាមាសៈ ទើបកើតឡើង។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវអំពើនោះ ត្រេកអរ រីករាយ រាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្សកើតឡើង ព្រោះប្រារព្ធនូវអំពើនោះ (នូវអំពើទាំងឡាយ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...ចេញអំពីឈាន (ពិចារណា) នូវឈាន ...ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ (ពិចារណា) នូវពួកកិលេសមិនមែនជាបរាមាសៈ ដែលលះបង់ហើយ ...នូវពួកកិលេសដែលសង្កត់សង្កិនហើយ ...ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ ...(ព្រះអរិយៈ) ពិចារណាឃើញនូវពួកខន្ធមិនមែនជាបរាមាសៈ ថាមិនទៀង ត្រេកអរ រីករាយ រាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ (ព្រះអរិយៈ) ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនោបរាមាសចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកខន្ធមិនមែនជាបរាមាសៈ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ អនាគតំសញ្ញាណ និងការពិចារណា ដោយអារម្មណប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ត្រេកអរ រីករាយ នឹងអំពើនោះ ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ក្នុងកាលមុន ...អំពីឈាន...។បេ។ នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ចំពោះពួកខន្ធមិនមែនជាបរាមាសៈ ទិដ្ឋិ

ប្រារព្ធនូវខន្ធនោះ...។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ត្រេកអរ រីករាយ នឹងអំពើនោះ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ចំពោះពួកខន្ធមិនមែនជាបរាមាសៈ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺប្រារព្ធនូវបរាមាសៈផង នូវពួកសម្បយុត្តកក្ខន្ធផង ...មានវារៈ៣។

[២៦១] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ គឺបរាមាសៈ (កើតឡើង) ព្រោះធ្វើនូវបរាមាសៈឲ្យជាទីគោរព បានដល់អារម្មណាធិបតិហ្នឹងឯង បណ្ឌិតគប្បីធ្វើឲ្យមានវារៈ៣ចុះ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...បុគ្គលពិចារណា ត្រេកអរ រីករាយ ព្រោះធ្វើនូវកុសលកម្មនោះ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ក្នុងកាលមុន ...អំពីឈាន ...ពួកអរិយៈចេញអំពីមគ្គ ហើយធ្វើនូវមគ្គឲ្យជាទីគោរព ...នូវផលឲ្យជាទីគោរព ...នូវព្រះនិព្វានឲ្យជាទីគោរព ...ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធមិនមែនជាបរាមាសៈ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវអំពើនោះឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាបរាមាសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ

និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន...។បេ។ នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធមិនមែនជាបរាមាសៈឲ្យជាទីគោរព ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព...។បេ។ ឯសហជាតាធិបតិ គឺអធិបតិមិនមែនជាបរាមាសៈ ជាបច្ច័យនៃបរាមាសៈ ដោយអធិបតិប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន...។បេ។ នូវចក្ខុ ...នូវវត្ថុ ...បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធមិនមែនជាបរាមាសៈ ឲ្យជាទីគោរព បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺអធិបតិមិនមែនជាបរាមាសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបរាមាសៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺបរាមាសៈ ធ្វើនូវបរាមាសៈផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរព ...មានវារៈ៣។

[២៦២] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអនន្តរប្បច្ច័យ គឺបរាមាសៈមុនៗ ជាបច្ច័យនៃបរាមាសៈក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតគប្បីធ្វើចុះ។ បរាមាសៈមុនៗ ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បរាមាសៈ ជាបច្ច័យនៃវុដ្ឋានៈ (ការចេញអំពីឈាន) ដោយអនន្តរប្បច្ច័យ។ មូល បណ្ឌិតគប្បីធ្វើចុះ បរាមាសៈមុនៗ ជាបច្ច័យនៃបរាមាសៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោបរាមាសក្ខន្ធមុនៗ

ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ ពួកនោបរាមាសក្ខន្ធមុនៗ ជាបច្ច័យនៃបរាមាសៈក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃបរាមាសៈ ដោយអនន្តរប្បច្ច័យ។ ពួកនោបរាមាសក្ខន្ធមុនៗ ជាបច្ច័យនៃបរាមាសៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអនន្តរប្បច្ច័យ គឺបរាមាសៈមុនៗផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃបរាមាសៈក្រោយៗ ដោយអនន្តរប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ បរាមាសៈមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ។ បរាមាសៈមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃបរាមាសៈក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ។ បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយសមនន្តរប្បច្ច័យ។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៥។

[២៦៣] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបរាមាសៈ ជាបច្ច័យនៃបរាមាសៈ ដោយឧបនិស្សយប្បច្ច័យ។ មានវារៈ៣។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានៈ

នូវសីល...។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានះ សេចក្តីប្រាថ្នា និងកាយិកសុខ ...អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា។បេ។ នៃបញ្ញា នៃរាគៈ។បេ។ នៃសេចក្តីប្រាថ្នា កាយិកសុខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ នូវបញ្ញា រាគៈ សេចក្តីប្រាថ្នា និងកាយិកសុខ ...អាស្រ័យនូវសេនាសនៈ ហើយប្រកាន់នូវទិដ្ឋិ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃបរាមាសៈ ដោយឧបនិស្សយប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយប្រកាន់នូវទិដ្ឋិ នូវសីល...។បេ។ អាស្រ័យនូវសេនាសនៈ ហើយប្រកាន់នូវទិដ្ឋិ សទ្ធា។បេ។ សេនាសនៈ ជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ឧបនិស្ស័យទាំង៣ គឺបរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃបរាមាសៈ ដោយឧបនិស្សយប្បច្ច័យ។ មានវារៈ៣។

[២៦៤] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គលពិចារណាឃើញនូវចក្ខុ ...នូវវត្ថុ ថាមិនទៀង ...ត្រេកអរ រីករាយ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។

ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធមិនមែនជាបរាមាសៈ ដោយបុរេជាតប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គល នឹងចក្ខុ ...ត្រេកអរ រីករាយនឹងវត្ថុ ទិដ្ឋិ (កើតឡើង) ព្រោះប្រារព្ធនូវវត្ថុនោះ...។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃបរាមាសៈ ដោយបុរេជាតប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គល នឹងចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ។

[២៦៥] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺវារៈទាំង៣ បណ្ឌិតគប្បីធ្វើឲ្យជាបច្ឆាជាត។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ មានវារៈ៩។

[២៦៦] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺនោបរាមាសចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺនោបរាមាសចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ នោបរាមាសចេតនា ជាបច្ច័យនៃបរាមាសៈ ដោយកម្មប្បច្ច័យ។ នោបរាមាសចេតនា ជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។

[២៦៧] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។ ជាបច្ច័យ ដោយអាហារប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៣។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៣។
[២៦៨] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយមគ្គប្បច្ច័យ បានដល់ពួកអង្គនៃមគ្គ ជាបរាមាសៈ ...បញ្ហាទាំង៥ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ៥។
[២៦៩] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃបរាមាសៈ ដោយវិប្បយុត្តប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺវត្ថុជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។
[២៧០] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សហជាត គឺបរាមាសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺបរាមាសៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។

សហជាត គឺពួកនោបរាមាសក្ខន្ធ ជាបច្ច័យនៃបរាមាសៈ ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺបុគ្គល នឹងចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ វត្ថុជាបច្ច័យនៃបរាមាសៈ ដោយអត្ថិប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺនោបរាមាសក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ផង នៃបរាមាសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ ឯបុរេជាត គឺបុគ្គល នឹងចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ វត្ថុ ជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃនោបរាមាសៈ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺនោបរាមាសក្ខន្ធ១ក្តី បរាមាសៈក្តី ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ...បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ គឺបរាមាសៈផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ បរាមាសៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធ ដោយអត្ថិប្បច្ច័យ។ បុរេជាត គឺបរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាត គឺបរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺបរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។

[២៧១] ក្នុងហេតុប្បច្ច័យ មានវារៈ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ៥

ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ៩ ក្នុងវិគតប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

[២៧២] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ

ដោយឧបនិស្សយប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។

[២៧៣] ក្នុងនហេតុប្បច្ច័យ មានវារៈ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៩។

[២៧៤] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៧៥] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៩។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ។ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

ចប់ បរាមាសទុកៈ

## បរាមដ្ឋទុកៈ

### បដិច្ចវារៈ

[២៧៦] បរាមដ្ឋធម៌ អាស្រ័យនូវបរាមដ្ឋធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវបរាមដ្ឋក្ខន្ធ១ នូវខន្ធ២ ...បដិសន្ធិដរាបដល់ពួកមហាភូតខាងក្នុង។ អាស្រ័យនូវបរាមដ្ឋធម៌...។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណា បរាមដ្ឋទុកៈ បណ្ឌិតគប្បីធ្វើយ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាឡើយ។

ចប់ បរាមដ្ឋទុកៈ។

## បរាមាសសម្បយុត្តទុកៈ

## បដិច្ចវារៈ

[២៧៧] បរាមាសសម្បយុត្តធម៌ អាស្រ័យនូវបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យគឺខន្ធ៣ អាស្រ័យនូវបរាមាសសម្បយុត្តក្ខន្ធ១ នូវខន្ធ២...។ បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកបរាមាសសម្បយុត្តកក្ខន្ធ។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី អាស្រ័យនូវបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវបរាមាសសម្បយុត្តក្ខន្ធ១ នូវខន្ធ២...។ បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមាសវិប្បយុត្តក្ខន្ធ១ នូវខន្ធ២ ...ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត១ ...បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសសម្បយុត្តធម៌ផង នូវបរាមាសវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកបរាមាសសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង។ សេចក្តីបំប្រួញ។

[២៧៨] ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ២ ក្នុងសហជាតប្បច្ច័យ មានវារៈ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ មានវារៈ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៥។ សេចក្តីបំប្រួញ។ ក្នុងមគ្គប្បច្ច័យ

មានវារៈ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ២ ក្នុងវិគតប្បច្ច័យ មានវារៈ២ ក្នុងអវិគតប្បច្ច័យ មានវារៈ៥។

[២៧៩] បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមាសវិប្បយុត្តក្ខន្ធ១ ជាអហេតុកៈ នូវខន្ធ២ ...អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ។

[២៨០] បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកបរាមាសសម្បយុត្តក្ខន្ធ។ បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកបរាមាសវិប្បយុត្តក្ខន្ធ ដរាបដល់ពួកអសញ្ញសត្វ។ បរាមាសវិប្បយុត្តធម៌ អាស្រ័យនូវបរាមាសសម្បយុត្តធម៌ផង នូវបរាមាសវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកបរាមាសសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង។ សេចក្តីបំប្រួញ។

[២៨១] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១

ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៨២] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៥។

បណ្ឌិត គប្បីរាប់យ៉ាងនេះចុះ។

[២៨៣] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអវិគតប្បច្ច័យ មានវារៈ១។

ឯសហជាតវារៈ ក៏ប្រហែលគ្នានឹងបដិច្ចវារៈដែរ។

**បច្ចយវារៈ**

[២៨៤] បរាមាសសម្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ៣ ដូចគ្នានឹងបដិច្ចវារៈដែរ។ បរាមាសវិប្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងបរាមាសវិប្បយុត្តក្ខន្ធ១ នឹងខន្ធ២ ...បដិសន្ធិដរាបដល់ពួកមហាភូតខាងក្នុង ពួកបរាមាសវិប្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ បរាមាសសម្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកបរាមាសសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកបរាមាសសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត។ បរាមាសសម្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសសម្បយុត្តធម៌ផង នឹងបរាមាសវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងបរាមាសសម្បយុត្តក្ខន្ធ១ផង នឹងវត្ថុផង នឹងខន្ធ២...។

បរាមាសវិប្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសសម្បយុត្តធម៌ផង និងបរាមាសវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកបរាមាសសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងបរាមាសសម្បយុត្តធម៌ផង នឹងបរាមាសវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងបរាមាសសម្បយុត្តក្ខន្ធ១ផង នឹងវត្ថុផង នឹងខន្ធ២ ...ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកបរាមាសសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង។ សេចក្តីបំប្រួញ។

[២៨៥] ក្នុងហេតុប្បច្ច័យ មានវារៈ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៤ ក្នុងនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ៤ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៩។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ៩។

[២៨៦] បរាមាសវិប្បយុត្តធម៌ ពឹងផ្អែកនឹងបរាមាសវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងបរាមាសវិប្បយុត្តក្ខន្ធ១ ជាអហេតុកៈ នឹងខន្ធ២ ...អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ ...ពួកបរាមាសវិប្បយុត្តក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង វត្ថុផង។

[២៨៧] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។

[២៨៨] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៩។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ។

[២៨៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ព្រោះនហេតុប្បច្ច័យ ...ក្នុងអវិគតប្បច្ច័យ មានវារៈ១។ និស្សយវារៈ ក៏ប្រហែលគ្នានឹងបច្ចយវារៈដែរ។

**សំសដ្ឋវារៈ**

[២៩០] បរាមាសសម្បយុត្តធម៌ លាយឡំនឹងបរាមាសសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ។

[២៩១] ក្នុងហេតុប្បច្ច័យ មានវារៈ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ២ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ២។

[២៩២] ក្នុងនហេតុប្បច្ច័យ មានវារៈ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ២ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ២ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ

មានវារៈ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២។ ការរាប់ទាំង២យ៉ាងក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ។

**បញ្ហាវារៈ**

[២៩៣] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកបរាមាសសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ។ ពួកបរាមាសសម្បយុត្តហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ។ ពួកបរាមាសសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកបរាមាសវិប្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ។

[២៩៤] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈ រាគៈកើតឡើង ព្រោះប្រារព្ធនូវរាគៈនោះ ត្រេកអរ រីករាយ ចំពោះពួកបរាមាសសម្បយុត្តក្ខន្ធ រាគៈកើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវពួកបរាមាសសម្បយុត្តក្កិលេស ដែលខ្លួនលះបង់ហើយ ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវកងកិលេស ដែលពុះពោរហើយ ក្នុងកាលមុន ពិចារណាឃើញនូវពួកបរាមាសសម្បយុត្តក្ខន្ធ ថាមិនទៀង ...ត្រេកអរ រីករាយ រាគៈ ដែលជាបរាមាសវិប្បយុត្ត វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ដឹងនូវចិត្តរបស់បុគ្គលដែលជាបរាមាសសម្បយុត្តសមង្គី ដោយចេតោបរិយញ្ញាណ ពួកបរាមាសសម្បយុត្តក្ខន្ធ ជាបច្ច័យនៃកិរិយា ពិចារណានូវចេតោបរិយញ្ញាណ

បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវបុញ្ញកម្ម មានទានជាដើមនោះ ត្រេកអរ រីករាយ (នឹងអំពើនោះ) រាគៈ ដែលជាបរាមាសវិប្បយុត្ត វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ...អំពីឈាន ...ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ នូវផល ...ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ (ពិចារណាឃើញ) នូវពួកបរាមាសវិប្បយុត្តកិលេស ដែលខ្លួនលះបង់ហើយ ...នូវកងកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ...ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ ...នូវពួកបរាមាសវិប្បយុត្តក្ខន្ធ ថាមិនទៀង... ពិចារណាឃើញ ត្រេកអរ រីករាយ បរាមាសវិប្បយុត្តរាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ស្គាល់នូវចិត្តរបស់បុគ្គល ដែលជាបរាមាសវិប្បយុត្តចិត្តសមង្គី ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកបរាមាសវិប្បយុត្តក្ខន្ធ ជាបច្ច័យនៃកិរិយាពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ត្រេកអរ

រីករាយ ចំពោះពួកបរាមាសវិប្បយុត្តក្ខន្ធ រាគៈកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ។

[២៩៥] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវរាគៈនោះ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវរាគៈនោះ ឲ្យជាទីគោរព ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកបរាមាសសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺបរាមាសសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺបុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកបរាមាសសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព បរាមាសវិប្បយុត្តរាគៈ កើតឡើង ព្រោះធ្វើនូវខន្ធនោះឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺបរាមាសសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ផង នៃបរាមាសវិប្បយុត្តធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺបរាមាសសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ធ្វើនូវបុញ្ញកម្ម មានទានជាដើមនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ បរាមាសវិប្បយុត្តរាគៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ក្នុងកាលមុន ...អំពីឈាន ...ពួកព្រះអរិយៈ ចេញអំពីមគ្គ (ហើយធ្វើ) នូវមគ្គ

ឲ្យជាទីគោរព ...នូវផល ...នូវនិព្វាន ...ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកបរាមាសវិប្បយុត្តក្ខន្ធ ឲ្យជាទីគោរព បរាមាសវិប្បយុត្តរាគ: កើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព។ ឯសហជាតាធិបតិ គឺបរាមាសវិប្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយត្រេកអរ រីករាយ ព្រោះធ្វើនូវបុញ្ញកម្មនោះ ឲ្យជាទីគោរព បរាមាសសម្បយុត្តរាគ: កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកបរាមាសវិប្បយុត្តក្ខន្ធ ឲ្យជាទីគោរព បរាមាសសម្បយុត្តរាគ: កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព។

[២៩៦] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកបរាមាសសម្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកបរាមាសសម្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកបរាមាសសម្បយុត្តក្ខន្ធ ជាបច្ច័យនៃវុដ្ឋាន: ដោយអនន្តរប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកបរាមាសវិប្បយុត្តក្ខន្ធមុនៗ
ជាបច្ច័យនៃពួកបរាមាសវិប្បយុត្តក្ខន្ធក្រោយៗ អនុលោម: ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ អាវជ្ជន: ជាបច្ច័យនៃពួកបរាមាសសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ។ ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ។

[២៩៧] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយសហជាតប្បច្ច័យ គឺមានវារៈ៥។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ២។ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺមានវារៈ៧។

[២៩៨] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបរាមាសសម្បយុត្តរាគៈ ...មោហៈ សេចក្តីប្រាថ្នា ...ជាបច្ច័យនៃបរាមាសសម្បយុត្តរាគៈ មោហៈ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវបរាមាសសម្បយុត្តរាគៈ ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ។បេ។ នូវបរាមាសសម្បយុត្តមោហៈ ...អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យនូវទាន ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងនូវមានះ សម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ បរាមាសសម្បយុត្តរាគៈ មោហៈ សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា។បេ។ នៃបញ្ញា រាគៈ ទោសៈ មោហៈ មានះ សេចក្តីប្រាថ្នា កាយិកសុខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ នូវសីល...។បេ។ នូវបញ្ញា រាគៈ និងមានះ ...អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យនូវទាន។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង សម្លាប់នូវសត្វ។បេ។ បំបែកនូវសង្ឃ នូវកាយិកសុខ ...អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន។បេ។ បំបែកនូវសង្ឃ សទ្ធា។បេ។ បញ្ញា រាគៈ មានះ សេចក្តីប្រាថ្នា កាយិកសុខ និងសេនាសនៈ ជាបច្ច័យនៃសទ្ធា បញ្ញា

រាគៈ មានៈ សេចក្តីប្រាថ្នា កាយិកសុខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។បេ។ ឯបកតូបនិស្ស័យ គឺរាគៈកើតឡើង ព្រោះអាស្រ័យនូវសទ្ធា នូវសីល។បេ។ សេចក្តីប្រាថ្នា សទ្ធា (កើតឡើង) ព្រោះអាស្រ័យនូវសេនាសនៈ។បេ។ សេនាសនៈ ជាបច្ច័យនៃបរាមាសសម្បយុត្តរាគៈ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។

[២៩៩] បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺនូវចក្ខុ ...នូវវត្ថុ ...ថាមិនទៀង ...ពិចារណាឃើញ ត្រេកអរ រីករាយ បរាមាសវិប្បយុត្តរាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកបរាមាសវិប្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺបុគ្គល នឹងចក្ខុ ...ត្រេកអរ រីករាយ នឹងវត្ថុ បរាមាសសម្បយុត្តរាគៈ កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកបរាមាសសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ។

[៣០០] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ។ សេចក្តីបំប្រួញ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ។ សេចក្តីបំប្រួញ។

[៣០១] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ២។

[៣០២] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺបរាមាសសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ។ សហជាត គឺបរាមាសសម្បយុត្តចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺបរាមាសសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ មូល បណ្ឌិតគប្បីសួរផងចុះ បរាមាសសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ។ សហជាត គឺបរាមាសវិប្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។ ឯនានាខណិកៈ គឺបរាមាសវិប្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ ជាបច្ច័យ ដោយវិបាកប្បច្ច័យ គឺមានវារៈ១។ ជាបច្ច័យ ដោយអាហារប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយឈានប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយមគ្គប្បច្ច័យ គឺមានវារៈ៤។ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ២។

[៣០៣] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត។ សេចក្តីបំប្រួញ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ

បានដល់បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកបរាមាសសម្បយុត្តកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ។

[៣០៤] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺបរាមាសសម្បយុត្តកក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២...។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺពួកបរាមាសសម្បយុត្តកក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ មូល បណ្ឌិតគប្បីធ្វើផងចុះ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ផង នៃបរាមាសវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺបរាមាសសម្បយុត្តកក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សេចក្តីបំប្រួញ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បុរេជាត គឺ នឹងចក្ខុ ...បុគ្គលត្រេកអរ រីករាយ នឹងវត្ថុ រាគៈ និងទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ វត្ថុជាបច្ច័យនៃពួកបរាមាសសម្បយុត្តក្ខន្ធ ដោយអត្ថិប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត។ សហជាត គឺបរាមាសសម្បយុត្តក្ខន្ធ១ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ៣ ដោយអត្ថិប្បច្ច័យ ខន្ធ២...។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ។ សហជាត គឺពួកបរាមាសសម្បយុត្តក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ បច្ឆាជាត គឺពួកបរាមាសសម្បយុត្តក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ

ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកបរាមាសសម្បយុត្តក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។

[៣០៥] ក្នុងហេតុប្បច្ច័យ មានវារៈ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ មានវារៈ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៤ ក្នុងឈានប្បច្ច័យ មានវារៈ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងវិគតប្បច្ច័យ មានវារៈ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ៧។

[៣០៦] បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ផង នៃបរាមាសវិប្បយុត្តធម៌ផង ដោយសហជាតប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌ ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ បរាមាសវិប្បយុត្តធម៌

ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃបរាមាសសម្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ បរាមាសសម្បយុត្តធម៌ក្តី បរាមាសវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃបរាមាសវិប្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។

[៣០៧] ក្នុងនហេតុប្បច្ច័យ មានវារៈ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងននិស្សយប្បច្ច័យ មានវារៈ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៧ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ៤។

[៣០៨] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះហេតុប្បច្ច័យ ...ក្នុងនអធិបតិប្បច្ច័យ មានវារៈ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៤ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ៤។

[៣០៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ៤ ព្រោះនហេតុប្បច្ច័យ ...ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើផងចុះ ...ក្នុងអវិគតប្បច្ច័យ មានវារៈ៧។

ចប់ បរាមាសសម្បយុត្តទុកៈ។

**បរាមាសបរាមដ្ឋទុកៈ**

**បដិច្ចវារៈ**

[៣១០] បរាមដ្ឋធម៌ និងនោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ និងបរាមដ្ឋធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវបរាមាសៈ។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ អាស្រ័យនូវបរាមដ្ឋធម៌ និងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវបរាមដ្ឋធម៌ និងនោបរាមាសក្ខន្ធ១ នូវខន្ធ២ ...ដរាបដល់ពួកមហាភូតខាងក្នុង ក្នុងខណៈនៃបដិសន្ធិ។ បរាមាសធម៌ និងបរាមដ្ឋធម៌ អាស្រ័យនូវបរាមដ្ឋធម៌ និងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបរាមាសៈ អាស្រ័យនូវពួកខន្ធជាបរាមដ្ឋៈ និងជានោបរាមាសៈ។ បរាមាសធម៌ និងបរាមដ្ឋធម៌ក្តី បរាមដ្ឋធម៌ និងនោបរាមាសធម៌ក្តី អាស្រ័យនូវបរាមដ្ឋធម៌ និងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង បរាមាសៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមដ្ឋក្ខន្ធ និងនោបរាមាសក្ខន្ធ១ នឹងខន្ធ២...។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ និងបរាមដ្ឋធម៌ផង នូវបរាមដ្ឋធម៌ និងនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមដ្ឋក្ខន្ធ និងនោបរាមាសក្ខន្ធ១ផង នូវបរាមាសៈផង នូវខន្ធ២...។ សេចក្តីបំប្រួញ។ វារៈទាំងអស់យ៉ាងណា បរាមាសទុកៈ បណ្ឌិតគប្បីធ្វើយ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងគ្នាឡើយ

**បញ្ហាវារៈ**

[៣១១] បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមដ្ឋធម៌ និងនោបរាមាសធម៌ ដោយហេតុប្បច្ច័យ គឺពួកបរាមដ្ឋហេតុ និងពួកនោបរាមាសហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ និងបរាមដ្ឋធម៌ ដោយហេតុប្បច្ច័យ គឺពួកបរាមដ្ឋហេតុ និងពួកនោបរាមាសហេតុ ជាបច្ច័យនៃបរាមាសៈ ដោយហេតុប្បច្ច័យ។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ និងបរាមដ្ឋធម៌ផង នៃបរាមដ្ឋធម៌ និងនោបរាមាសធម៌ផង ដោយហេតុប្បច្ច័យ គឺពួកបរាមដ្ឋហេតុ និងពួកនោបរាមាសហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបរាមាសៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[៣១២] បរាមាសធម៌ និងបរាមដ្ឋធម៌ ជាបច្ច័យនៃបរាមាសធម៌ និងបរាមដ្ឋធម៌ ដោយអារម្មណប្បច្ច័យ គឺមានវារៈ៣ (បរាមដ្ឋទុកៈ) ប្រហែលគ្នានឹងបរាមាសទុកៈដែរ បណ្ឌិតគប្បីប្រារព្ធ ហើយធ្វើចុះ។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមដ្ឋធម៌ និងនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...ធ្វើនូវឧបោសថកម្ម ហើយពិចារណា ត្រេកអរ រីករាយ នឹងអំពើនោះ រាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ក្នុងកាលមុន ...អំពីឈាន ...ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ ពិចារណានូវវោទានៈ នូវពួកកិលេស ដែលខ្លួនលះបង់ហើយ ...នូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ...ក្នុងកាលមុន ...នូវចក្ខុ ...នូវវត្ថុ ...នូវពួកបរាមដ្ឋក្ខន្ធ និងពួកនោបរាមាសក្ខន្ធ ថាមិនទៀង ...ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ដរាបដល់អាវជ្ជនៈ មូលទាំងអស់ បណ្ឌិតគប្បីធ្វើចុះ។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ និងបរាមដ្ឋធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម... ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ត្រេកអរ រីករាយ

ចំពោះពួកបរាមដ្ឋក្ខន្ធ និងពួកនោបរាមាសក្ខន្ធ ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ...។ បរាមដ្ឋធម៌ និងនោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ និងនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ...នូវសីល ...នូវឧបោសថកម្ម ...ក្នុងកាលមុន ...អំពីឈាន ...នូវចក្ខុ ...នូវវត្ថុ ...ពិចារណាឃើញ ត្រេកអរ រីករាយ ចំពោះពួកបរាមដ្ឋក្ខន្ធ និងពួកនោបរាមាសក្ខន្ធ ថាមិនទៀង ...បរាមាសៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ។ សូម្បីក្នុងវារៈដទៃ បណ្ឌិតក៏គប្បីប្រារព្ធវារៈទាំង៣ ហើយធ្វើយ៉ាងនេះដែរ។ ទុកៈនេះ ប្រហែលគ្នានឹងបរាមាសទុកៈដែរ។ លោកុត្តរៈ ដែលបណ្ឌិតមិនគប្បីបានក្នុងទុកៈណា ក៏មិនគប្បីធ្វើក្នុងទុកៈនោះ។

ចប់ បរាមាសបរាមដ្ឋទុកៈ។

## បរាមាសវិប្បយុត្តបរាមដ្ឋទុកៈ

## បដិច្ចវារៈ

[៣១៣] បរាមាសវិប្បយុត្តបរាមដ្ឋធម៌ អាស្រ័យបរាមាសវិប្បយុត្តបរាមដ្ឋធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមាសវិប្បយុត្តបរាមដ្ឋក្ខន្ធ១ នូវខន្ធ២...។ បរាមាសវិប្បយុត្តអបរាមដ្ឋធម៌ អាស្រ័យនូវបរាមាសវិប្បយុត្តអបរាមដ្ឋធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។

លោកិយទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណាមិញ បណ្ឌិតគប្បីធ្វើយ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាឡើយ។

ចប់ បរាមាសវិប្បយុត្តបរាមដ្ឋទុកៈ។

ចប់ អនុលោមទុកប្បដ្ឋាន ខាងដើម។

**ចប់ ភាគ១០១។**